# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម

២៦-៣-២០១៥ -ព្រះរាជក្រម នស/រកម/០៣១៥/០០២ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការ-បោះឆ្នោត ២៦៩៦

### ២~ព្រះរាជក្រឹត្យ

១៦-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២០៨ ស្តីពី ការផ្ទេរក្របខ័ណ្ឌ និងតែងតាំងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ ជូនឯកឧត្តម **ទិត ឈុនដា** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ២៧១៩

១៩-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២១៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ អ្នកគ្រូ **នាង ផល្លា** ២៧២០

១៩-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២១៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ព្រះសង្ឃ និងអស់លោក ចំនួន ១៣ អង្គ /រូប ២៧២១

១៩-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២១៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ព្រះសង្ឃ ឧកញ៉ា និងអស់លោក ចំនួន ២៧ អង្គ /រូប ២៧២២

១៩-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២១៩ ស្តីពី ការតម្លើងឋានៈឯកឧត្តម **ជុង ហ៊ន់ទូ** ទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី ៣ មានឋានៈស្មើ រដ្ឋលេខាធិការ ២៧២៣

១៩-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២២០ ស្តីពី ការតែងតាំងឯកឧត្តម **ឈិន យ៉ុងសៀង** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី ៣ មានឋានៈស្មើ រដ្ឋលេខាធិការ ២៧២៤

១៩-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២២១ ស្តីពី ការតែងតាំងលោកស្រី **ស៊ុំ ហៀង** ជាឧកញ៉ា ២៧២៥

១៩-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២២២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ព្រះសង្ឃ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី កញ្ញា និងកងកម្លាំងប្រដាប់អាវុធ ចំនួន ២៤៥ អង្គ /រូប ២៧២៦

២៣-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២២៣ ស្តីពី ការតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ឯក **ឈុប ទី** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក ២៧៣១

២៣-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២២៤ ស្តីពី ការតែងតាំងឯកឧត្តម **ឈឹម សំអាត** ជាទីប្រឹក្សាអមក្រសួងផែនការ មានឋានៈស្មើ អគ្គនាយក ២៧៣២


## II ~ក្រុមប្រឹក្សាធម្មនុញ្ញ


២៤-៣-២០១៥ -សេចក្តីសម្រេចលេខ ១៥៣/00១/២០១៥ កបធ.ច ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៥ លើសំណុំរឿង លេខ ២៥៤/00១/២០១៥ ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៥ ២៧៣៣

២៤-៣-២០១៥ -សេចក្តីសម្រេចលេខ ១៥៤/00២/២០១៥ កបធ.ច ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៥ លើសំណុំរឿង លេខ ២៥៥/00២/២០១៥ ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៥ ២៧៣៧


## III~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


១៨-៣-២០១៥ -អនុក្រឹត្យលេខ ២៩៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២៧៤៣

១៨-៣-២០១៥ -អនុក្រឹត្យលេខ ២៩៦ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៧៤៤

១៨-៣-២០១៥ -អនុក្រឹត្យលេខ ២៩៧ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ២៧៤៥

១៩-៣-២០១៥ -អនុក្រឹត្យលេខ ២៩៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២៧៤៧

១៩-៣-២០១៥ -អនុក្រឹត្យលេខ ២៩៩ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ២៧៤៩

១៩-៣-២០១៥ -អនុក្រឹត្យលេខ ៣00 អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២៧៥0

១៩-៣-២០១៥ -អនុក្រឹត្យលេខ ៣0១ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ២៧៥២

១៩-៣-២០១៥ -អនុក្រឹត្យលេខ ៣0២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២៧៥៤

១៩-៣-២០១៥ -អនុក្រឹត្យលេខ ៣0៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ អមធនាគារអភិវឌ្ឍន៍ជនបទ ២៧៥៦

២0-៣-២០១៥ -អនុក្រឹត្យលេខ ៣0៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីនគរបាលជាតិកម្ពុជា ២៧៥៨

២០-៣-២០១៥ -អនុក្រឹត្យលេខ ៣០៥ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៧៥៩
២០-៣-២០១៥ -អនុក្រឹត្យលេខ ៣០៦ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ២៧៦០
២០-៣-២០១៥ -អនុក្រឹត្យលេខ ៣០៧ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ២៧៦១
២០-៣-២០១៥ -អនុក្រឹត្យលេខ ៣០៨ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ២៧៦៣
២០-៣-២០១៥ -អនុក្រឹត្យលេខ ៣០៩ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ២៧៦៦
២០-៣-២០១៥ -អនុក្រឹត្យលេខ ៣១០ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ២៧៧១
២០-៣-២០១៥ -អនុក្រឹត្យលេខ ៣១១ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ២៧៧២
២០-៣-២០១៥ -អនុក្រឹត្យលេខ ៣១២ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ២៧៧៣
២០-៣-២០១៥ -អនុក្រឹត្យលេខ ៣១៣ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ២៧៧៥
២០-៣-២០១៥ -អនុក្រឹត្យលេខ ៣១៤ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៧៧៨
២៣-៣-២០១៥ -អនុក្រឹត្យលេខ ៣១៥ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិកម្ពុជា ២៧៧៩
២៤-៣-២០១៥ -អនុក្រឹត្យលេខ ៣១៦ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ២៧៨០

## ២-សេចក្ដីសម្រេច

២៤-៣-២០១៥ -សេចក្ដីសម្រេចលេខ២១ សសរ ស្ដីពី ការបង្កើតគណៈកម្មការបច្ចេកទេសសម្រាប់គម្រោងសាងសង់ពហុកីឡាដ្ឋានជាតិមរតកតេជោ ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណង ពីសាធារណរដ្ឋប្រជាមានិតចិន ២៧៨១
២៥-៣-២០១៥ -សេចក្ដីសម្រេចលេខ ២២ សសរ ស្ដីពី ការបង្កើតរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស សានកូប៉ោយប៉ែត ២៧៨៤
២៦-៣-២០១៥ -សេចក្ដីសម្រេចលេខ ២៣ សសរ ស្ដីពី ការរៀបចំចងសម្ព័ន្ធមេត្រីភាព រវាងកងពលតូចអន្តរាគមន៍ លេខ ១៤ ជាមួយ អគ្គិសនីកម្ពុជា និងអាជ្ញាធរអគ្គិសនីកម្ពុជា ២៧៨៧
*-សេចក្ដីសម្រេចលេខ ២៤ សសរ មិនទាន់បានទទួល*

## IV -ការងារបណ្ដាក្រសួង

### ១-ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៤-៣-២០១៥ -ប្រកាសលេខ ២៥៦ សហវ.ប្រក ស្ដីពី ការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនអគ្គនាយក នៃគណៈកម្មការមូលបត្រកម្ពុជា ២៧៨៨

០៤-៣-២០១៥ -ប្រកាសលេខ ២៩៧ សហវ.ប្រក ស្ដីពី ការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ២៧៩១

០៤-៣-២០១៥ -ប្រកាសលេខ ២៩៨ សហវ.ប្រក ស្ដីពី ការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ ២៧៩៤

០៥-៣-២០១៥ -ប្រកាសលេខ ២៦៥ សហវ.ប្រក ស្ដីពី ការកែសម្រួលប្រការ ៦ នៃប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៤ ស្ដីពី ការកំណត់គោលការណ៍យន្តការ នីតិវិធី និងការត្រួតពិនិត្យសម្រាប់ការផ្ដល់ការលើកទឹកចិត្តដោយប្រើប្រាស់ប្រាក់រង្វាន់របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២៧៩៧

១០-៣-២០១៥ -ប្រកាសលេខ ២៧៥ សហវ.ប្រក ស្ដីពី នីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ២៨០០

## ២-ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១២-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៨៤ ពណ.ចបព ស្ដីពី ការទទួលចុះបញ្ជីនូវការកែប្រែ និងតម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **ជី ស៊ែលទេសិន (ខេមបូឌា) អេសិត** ២៨២៤

១២-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៨៥ ពណ.ចបព ស្ដីពី ការទទួលចុះបញ្ជីនូវការកែប្រែ និងតម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **ឌី ឡូជីស ឌីវេឡុបម៉ិន លីមីធីត** ២៨២៦

១២-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៨៦ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឭ ដុង ស៊ីរ៉ោន ឡេក ឡែន ឌីវេឡុបម៉ិន** ២៨២៨

១២-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៨៧ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ខេជក្វ (ខេមបូឌា)** ២៨៣០

១២-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៨៨ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អេធើលីយេ អហ្វ អឺបេន អាឃីធេកឈ័រ អេនជីនារីង** ២៨៣២

១២-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៨៩ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **គ្លូប៊ល អ៊ីខឡូជីខល រ៉ាយស៍ (ខេមបូឌា)** ២៨៣៤

# ព្រះរាជក្រម

នស/រកម/០៣១៥/០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំលើកទី៦ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៥៣/០០១/២០១៥ កបធ.ច ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃ
# គណៈកម្មាធិការជាតិ
# រៀបចំការបោះឆ្នោត

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីរៀបចំ ចាត់ចែង និងគ្រប់គ្រងការបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងការបោះឆ្នោតផ្សេងទៀត តាមការកំណត់នៃច្បាប់ ។

**មាត្រា ២.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានឈ្មោះជាអក្សរកាត់ "គ.ជ.ប" ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវមានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត និងគណៈកម្មការការិយាល័យបោះឆ្នោត ដើម្បីអនុវត្តការងាររបស់ខ្លួន ។

**មាត្រា ៣.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវអនុវត្តសមត្ថកិច្ចរបស់ខ្លួន ដោយឯករាជ្យ និងអព្យាក្រឹត ដើម្បីធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស ។

សមាជិកទាំងឡាយនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសមាជិក នៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវមានជំហរអព្យាក្រឹតឥតលម្អៀងក្នុងការអនុវត្តការងារបោះឆ្នោត ។

## ជំពូកទី ២
## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

### ផ្នែកទី ១
### ការរៀបចំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**មាត្រា ៤.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមាសភាព ០៩ (ប្រាំបួន) រូប ដែលរួមមាន ៖

- ប្រធាន ០១ (មួយ) រូប

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

-អនុប្រធាន ០១ (មួយ) រូប

-សមាជិក ០៧ (ប្រាំពីរ) រូប ។

**មាត្រា ៥.-**

សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនខ្មែរទាំងពីរភេទ ដែលមានលក្ខណសម្បត្តិ ដូចខាងក្រោម ៖

-មានសញ្ជាតិខ្មែរពីកំណើត និងមានសញ្ជាតិខ្មែរតែមួយគត់ ក្នុងពេលបំពេញការងារនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-មានអាយុយ៉ាងតិច ៣៥ (សាមសិបប្រាំ) ឆ្នាំ គិតដល់ថ្ងៃតែងតាំង

-មានសិទ្ធិបោះឆ្នោត

-មានសញ្ញាបត្រចាប់ពីថ្នាក់ឧត្តមសិក្សាឡើងទៅ

-មានបទពិសោធន៍ការងារយ៉ាងតិច ១០ (ដប់) ឆ្នាំ

-មិនត្រូវជាសហព័ទ្ធ ឬញាតិលោហិត ឬញាតិពន្ធរហូតដល់ថ្នាក់ទី ៣ របស់ប្រធាន អនុប្រធានគណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត ។

**មាត្រា ៦.-**

សមាសភាពទាំង ០៩ (ប្រាំបួន) រូប នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវជ្រើសរើសដោយ ៖

-០៤ (បួន) រូប ជ្រើសរើសដោយគណបក្សដឹកនាំរាជរដ្ឋាភិបាល

-០៤ (បួន) រូប ជ្រើសរើសដោយគណបក្សមានអាសនៈក្នុងរដ្ឋសភា ដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល និង

-០១ (មួយ) រូបទៀត ជ្រើសរើសដោយមានការព្រមព្រៀងគ្នារវាងគណបក្សទាំងអស់ដែលមានអាសនៈក្នុងរដ្ឋសភា ។

ផ្អែកតាមគោលការណ៍ខាងលើនេះ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវធ្វើការសម្របសម្រួលជាមួយគណបក្សនយោបាយទាំងអស់ ដែលមានអាសនៈក្នុងរដ្ឋសភា ដើម្បីប្រកាសជ្រើសរើសបេក្ខជនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាសាធារណៈ ប្រកបដោយលក្ខណៈបើកចំហ និងមានតម្លាភាព ក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ថ្ងៃ ។ បន្ទាប់មក គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវសម្របសម្រួលជាមួយគណបក្សទាំងអស់ ដែលមានអាសនៈក្នុងរដ្ឋសភា ដើម្បី

ពិនិត្យជ្រើសរើសបេក្ខជនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពីក្នុងចំណោមបេក្ខជនដែលបានដាក់ពាក្យស្នើសុំ ដោយផ្អែកតាមលក្ខណសម្បត្តិ ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ។

បែបបទ និងនីតិវិធីនៃការជ្រើសរើសបេក្ខជនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ។

ផ្អែកលើសមាសភាពដែលបានជ្រើសរើសខាងលើនេះ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវរៀបចំបញ្ជីសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជូនរដ្ឋសភា ដើម្បីបោះឆ្នោតទុកចិត្តតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតែងតាំងដោយព្រះរាជក្រឹត្យយ៉ាងយូរ ០៦ (ប្រាំមួយ) ខែ បន្ទាប់ពីរដ្ឋសភាថ្មីចូលកាន់តំណែង ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ។

**មាត្រា ៧.-**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានអាណត្តិ ០៥ (ប្រាំ) ឆ្នាំ ហើយត្រូវផុតអាណត្តិនៅពេលសមាសភាពថ្មីចូលកាន់តំណែង ។

ក្នុងករណីដែលខកខានមិនបានរៀបចំសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានស្រាប់ ត្រូវអនុវត្តការងាររបស់ខ្លួនបន្តទៀត និងមានសមត្ថកិច្ច ដើម្បីចាត់ចែងរៀបចំបោះឆ្នោតស្របតាមច្បាប់ជាធរមាន ។

**មាត្រា ៨.-**

មុខងារជាប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានវិសមិតភាពជាមួយការបំពេញមុខតំណែងក្នុងមុខងារសាធារណៈ និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានព្យួរសិទ្ធិបោះឆ្នោតជាបណ្តោះអាសន្ន រហូតដល់ថ្ងៃបញ្ចប់មុខតំណែង ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលជាសមាជិកនៃគណបក្សនយោបាយ ត្រូវសុំលាលែងពីគណបក្សនយោបាយ ហើយអាចចូលជាសមាជិកគណបក្សនយោបាយវិញបាន ក្នុងរយៈពេលយ៉ាងតិច ០២ (ពីរ) ឆ្នាំ បន្ទាប់ពីបញ្ចប់អាណត្តិការងារ ឬបាត់បង់មុខតំណែងឬត្រូវបានបណ្តេញចេញ ដូចមានចែងក្នុងមាត្រា ៧ មាត្រា ៩ និងមាត្រា ១០ នៃច្បាប់នេះ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលជាសមាជិក ឬ/និងជាអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងក្រុមហ៊ុនពាណិជ្ជកម្ម ឬ/និងមន្ត្រីរាជការ ត្រូវសុំលាលែងពីអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងក្រុមហ៊ុនពាណិជ្ជកម្ម ឬ/និងត្រូវដាក់ពាក្យសុំទៅបម្រើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ថ្ងៃចប់អាណត្តិ ។

**មាត្រា ៩.-**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបាត់បង់មុខតំណែងក្នុងករណីណាមួយ ដូចខាងក្រោម៖

-សាមីខ្លួន ទទួលមរណភាព

-សាមីខ្លួន សុំលាឈប់ជាលាយលក្ខណ៍អក្សរ

-សាមីខ្លួន បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច

-សាមីខ្លួន ត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។

**មាត្រា ១០.-**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវមានគណនេយ្យភាពចំពោះមុខរដ្ឋសភា ។

ការសម្រេចបណ្តេញចេញពីប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាសមត្ថកិច្ចរបស់រដ្ឋសភា ។

**មាត្រា ១១.-**

ក្នុងករណីដែលមានប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបាត់បង់ពីមុខតំណែង គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវសម្របសម្រួលជាមួយគណបក្សនយោបាយពាក់ព័ន្ធ ដើម្បីប្រកាសជ្រើសរើសជាសាធារណៈនូវបេក្ខភាពបេក្ខជនដែលត្រូវជំនួសមុខតំណែងដែលទំនេរ ប្រកបដោយលក្ខណៈបើកចំហ និងមានតម្លាភាព ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ ។

បន្ទាប់មក គណបក្សពាក់ព័ន្ធត្រូវជ្រើសរើសសមាសភាពថ្មីពីក្នុងចំណោមអ្នកដែលបានដាក់ពាក្យក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ ដាក់ទៅគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដើម្បីគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភារៀបចំដាក់សមាសភាពថ្មីនេះ ជូនរដ្ឋសភាបោះឆ្នោតទុកចិត្ត តាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ ក្នុងករណីដែលមានការរៀបចំបោះឆ្នោត និងយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃ ក្នុងករណី ដែលគ្មានការរៀបចំបោះឆ្នោត ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ករណីគណបក្សនយោបាយពាក់ព័ន្ធខកខានមិនបានជ្រើសរើសសមាសភាពថ្មីតាមការកំណត់ខាងលើ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវធ្វើការជ្រើសរើសបេក្ខភាពបេក្ខជន ដែលត្រូវជំនួសមុខតំណែងទំនេរនោះ ដោយផ្អែកតាមលក្ខណសម្បត្តិ ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ពីក្នុងចំណោមអ្នកដែលបានដាក់ពាក្យ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ប្រកបដោយលក្ខណៈបើកចំហ និងមានតម្លាភាពក្នុងរយៈពេលយ៉ាងតិច ០២ (ពីរ) ថ្ងៃ ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោតទុកចិត្តតាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ក្នុងរយៈពេលយ៉ាងយូរ ០២ (ពីរ) ថ្ងៃ ក្នុងករណីដែលមានការរៀបចំបោះឆ្នោត និងយ៉ាងយូរ ០៣ (បី) ថ្ងៃ ក្នុងករណីដែលគ្មានការរៀបចំបោះឆ្នោត ។

បែបបទ នីតិវិធីនៃការដាក់ពាក្យ ការជ្រើសរើស និងការរៀបចំបញ្ជីបេក្ខជនដាក់ជូនរដ្ឋសភាត្រូវកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ។

ប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានទទួលការតែងតាំងជំនួសកន្លែងទំនេរនោះ ត្រូវធ្វើសច្ចាប្រណិធានចូលកាន់តំណែងភ្លាម ។

ប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលត្រូវបានតែងតាំងជំនួសកន្លែងទំនេរនោះ មានអាណត្តិត្រឹមអាណត្តិដែលនៅសល់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## មាត្រា ១២.-

ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើឧបនាយករដ្ឋមន្ត្រី ។

អនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើទេសរដ្ឋមន្ត្រី ។

សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើរដ្ឋមន្ត្រី ។

## មាត្រា ១៣.-

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអនុវត្តតួនាទីរបស់ខ្លួនដោយមិនលម្អៀង ដោយឈរលើគោលការណ៍គោរពច្បាប់ដោយមិនទទួលការគាបសង្កត់ ការគំរាមកំហែង ការបំភិតបំភ័យ ឬការបង្គាប់បញ្ជាដោយផ្ទាល់ ឬដោយប្រយោលពីបុគ្គល ឬស្ថាប័នណាមួយឡើយ ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបានការធានាការពារសន្តិសុខ សុវត្ថិភាពផ្ទាល់ខ្លួន និងគ្រួសារ ក្នុងករណីចាំបាច់ តាមសំណូមពររបស់សាមីខ្លួន ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនត្រូវទទួលខុស

ត្រូវខាងបទព្រហ្មទណ្ឌ ឬបទរដ្ឋប្បវេណីណាមួយ ចំពោះការសម្រេចដែលបានធ្វើក្នុងក្របខ័ណ្ឌសមត្ថកិច្ច និងមុខងាររបស់ខ្លួនឡើយ ។

## ផ្នែកទី ២
## ការរៀបចំគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត

**មាត្រា ១៤.-**

គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោតមានសមាសភាព ដូចខាងក្រោម ៖

-ប្រធាន ០១ (មួយ) រូប

-អនុប្រធាន ០១ (មួយ) រូប

-សមាជិក ០៣ (បី) ឬ ០៥ (ប្រាំ) រូប ។

ចំនួនជាក់ស្តែងនៃសមាជិកគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត តាមរាជធានី ខេត្តនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១៥.-**

ប្រធានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើនឹងប្រធាននាយកដ្ឋាននៃក្រសួង ស្ថាប័ន ។

អនុប្រធានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើនឹងអនុប្រធាននាយកដ្ឋាននៃក្រសួង ស្ថាប័ន ។

សមាជិកគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោតត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើនឹងប្រធានការិយាល័យនៃក្រសួង ស្ថាប័ន ។

**មាត្រា ១៦.-**

សមាសភាពគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវជ្រើសរើសឡើងក្នុងចំណោមប្រជាពលរដ្ឋ ឬ/និងមន្ត្រីរាជការក្នុងរាជធានី ខេត្តដែលមានសិទ្ធិបោះឆ្នោត លើកលែងតែកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោតសម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ មេភូមិ ជំនួយការមេភូមិ និងជនដែលត្រូវបានតុលាការផ្តន្ទាទោសជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ។

**មាត្រា ១៧.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់តាំងគណៈកម្មការមួយ ដើម្បីធ្វើការជ្រើសរើសសមាសភាពគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ប្រកបដោយលក្ខណៈបើកចំហ និងមានតម្លាភាព ។

បែបបទ និងនីតិវិធីជាក់ស្តែងនៃដំណើរការជ្រើសរើសសមាសភាពគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១៨.-**

គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១៩.-**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ដែលជាសមាជិកគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែន រដ្ឋាភិបាល សមាគម សហជីព ឬ/និងមន្ត្រីរាជការ ក្រោយពីបានទទួលការតែងតាំង ត្រូវសុំលាលែងពីសមាជិកនៃគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងត្រូវដាក់ពាក្យសុំទៅបម្រើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ថ្ងៃចប់ភារកិច្ច ។

**មាត្រា ២០.-**

ប្រធាន អនុប្រធាន ឬសមាជិកគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោតត្រូវបាត់បង់ពីមុខតំណែងក្នុងករណីណាមួយ ដូចខាងក្រោម ៖

-សាមីខ្លួន ទទួលមរណភាព

-សាមីខ្លួន សុំលាឈប់ជាលាយលក្ខណ៍អក្សរ

-សាមីខ្លួន បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័ន មានសមត្ថកិច្ច

–សាមីខ្លួន ត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។

**មាត្រា ២១.-**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោតត្រូវមានគណនេយ្យភាពចំពោះមុខគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសិទ្ធិសម្រេចបណ្តេញប្រធាន អនុប្រធាន និង សមាជិកគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោតណាមួយ ក្នុងករណីប្រព្រឹត្តផ្ទុយពីច្បាប់ស្តីពី ការបោះឆ្នោតជាធរមាន បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោត ឬក្រមសីលធម៌ សម្រាប់មន្ត្រីបោះឆ្នោត ។

**មាត្រា ២២.-**

សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មការរាជធានី ខេត្ត ត្រូវបំពេញការងាររបស់ខ្លួនរហូតដល់ ៦០ (ហុកសិប) ថ្ងៃ ក្រោយពីការ ប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ។

សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវបំពេញការងាររបស់ខ្លួនរហូតដល់ ៣០ (សាមសិប) ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ។

**មាត្រា ២៣.-**

គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវមានលេខាធិការដ្ឋានមួយ ជាជំនួយការ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការ បោះឆ្នោត ។

**មាត្រា ២៤.-**

ក្នុងចន្លោះពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយទៀត គណៈកម្មាធិការជាតិរៀបចំការ បោះឆ្នោត ត្រូវចាត់ឲ្យមន្ត្រីលេខាធិការដ្ឋានមួយចំនួន បន្តការងារ ដើម្បីធានានិរន្តរភាពនៃការងារបោះ ឆ្នោតតាមរាជធានី ខេត្តនីមួយៗ ។

**មាត្រា ២៥.-**

គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោតមានតួនាទី ភារកិច្ចដូចតទៅ ៖

១-អនុវត្តភារកិច្ចដែលច្បាប់ បទបញ្ជា នីតិវិធីនៃការបោះឆ្នោត និងលិខិតបទដ្ឋាននានាដែលបាន អនុញ្ញាត ឬតម្រូវឲ្យអនុវត្ត ។

២-អនុវត្តភារកិច្ច និងសិទ្ធិដទៃទៀតដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រគល់ឲ្យ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ផ្នែកទី ៣
## ការរៀបចំគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត

**មាត្រា ២៦.-**

គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតមានសមាសភាព ដូចខាងក្រោម៖

-ប្រធាន ០១ (មួយ) រូប

-អនុប្រធាន ០១ (មួយ) រូប

-សមាជិក ០៣ (បី) ឬ ០៥ (ប្រាំ) រូប ។

ចំនួនជាក់ស្តែងនៃសមាជិកគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតតាមឃុំ សង្កាត់នីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ២៧.-**

សមាសភាពគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតត្រូវជ្រើសរើសឡើងក្នុងចំណោមប្រជាពលរដ្ឋ ឬ/និងមន្ត្រីរាជការក្នុងក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ លើកលែងតែកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោតសម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ មេភូមិ ជំនួយការមេភូមិ និងជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ។

**មាត្រា ២៨.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់តាំងគណៈកម្មការមួយ ដើម្បីធ្វើការជ្រើសរើសសមាសភាពគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតប្រកបដោយលក្ខណៈបើកចំហ និងមានតម្លាភាព ។

បែបបទ និងនីតិវិធីជាក់ស្តែងនៃដំណើរការជ្រើសរើសសមាសភាពគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ២៩.-**

គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត តាមសំណើរបស់គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោតដោយផ្អែកលើលទ្ធផលនៃការជ្រើសរើសសមាសភាពគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតរបស់គណៈកម្មការជ្រើសរើស ដូចមានចែងក្នុងមាត្រា ២៨ នៃច្បាប់នេះ ។

**មាត្រា ៣០.-**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ដែលជាសមាជិកគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងមន្ត្រីរាជការក្រោយពីបានទទួលការតែងតាំង ត្រូវសុំលាលែងពីសមាជិកនៃគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងត្រូវដាក់ពាក្យសុំទៅបម្រើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ថ្ងៃចប់ភារកិច្ច ។

**មាត្រា ៣១.-**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ត្រូវបាត់បង់ពីមុខតំណែងក្នុងករណីណាមួយ ដូចខាងក្រោម ៖

-សាមីខ្លួន ទទួលមរណភាព

-សាមីខ្លួន សុំលាឈប់ជាលាយលក្ខណ៍អក្សរ

-សាមីខ្លួន បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមាន សមត្ថកិច្ច

-សាមីខ្លួន ត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។

**មាត្រា ៣២.-**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ត្រូវមានគណនេយ្យភាពតាមឋានានុក្រមចំពោះមុខគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសិទ្ធិសម្រេចបណ្តេញប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតណាមួយ ក្នុងករណីប្រព្រឹត្តផ្ទុយពីច្បាប់ស្តីពីការបោះឆ្នោតជាធរមាន បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោត ឬក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចចេញសេចក្តីសម្រេចធ្វើប្រតិភូកម្មអំណាចជូនគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត តាមការចាំបាច់ ដើម្បីអនុវត្តបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រានេះ ។

**មាត្រា ៣៣.-**

គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតមានតួនាទីភារកិច្ច ដូចតទៅ ៖

១-អនុវត្តភារកិច្ចដែលច្បាប់ បទបញ្ជា នីតិវិធីនៃការបោះឆ្នោត និងលិខិតបទដ្ឋាននានាដែលបានអនុញ្ញាត ឬតម្រូវឲ្យអនុវត្ត ។

២-អនុវត្តភារកិច្ច និងសិទ្ធិដទៃទៀតដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រគល់ឲ្យ ។

## ផ្នែកទី ៤
## ការរៀបចំគណៈកម្មការការិយាល័យបោះឆ្នោត

**មាត្រា ៣៤.-**

គណៈកម្មការការិយាល័យបោះឆ្នោតនីមួយៗ មានសមាសភាព ដូចខាងក្រោម ៖

| | |
|---|---|
| -ប្រធាន | ០១ (មួយ) រូប |
| -អនុប្រធាន | ០១ (មួយ) រូប |
| -លេខាធិការ | ០១ (មួយ) រូប |
| -សមាជិក | ០៣ (បី) រូប ។ |

**មាត្រា ៣៥.-**

សមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវជ្រើសរើសឡើងក្នុងចំណោមប្រជាពលរដ្ឋ ឬ/និងមន្ត្រីរាជការក្នុងក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ លើកលែង តែកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោតសម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ មេភូមិ ជំនួយការមេភូមិ និងជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ។

**មាត្រា ៣៦.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់តាំងគណៈកម្មការមួយ ដើម្បីធ្វើការជ្រើសរើសសមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត ប្រកបដោយលក្ខណៈបើកចំហ និងមានតម្លាភាព ។

បែបបទ និងនីតិវិធីជាក់ស្តែងនៃដំណើរការជ្រើសរើសសមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៣៧.-**

គណៈកម្មការការិយាល័យបោះឆ្នោត ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមសំណើរបស់គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ដោយផ្អែកលើលទ្ធផលនៃការជ្រើសរើសសមាសភាពគណៈកម្មការការិយាល័យបោះឆ្នោតរបស់គណៈកម្មការជ្រើសរើស ដូចមានចែងក្នុងមាត្រា ៣៦ នៃច្បាប់នេះ ។

**មាត្រា ៣៨.-**

ប្រធាន អនុប្រធាន លេខាធិការ និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោតដែលជាសមាជិកគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព

ឬ/និងមន្ត្រីរាជការ ក្រោយពីបានទទួលការតែងតាំង ត្រូវសុំលាលែងជាបណ្តោះអាសន្នពីសមាជិកនៃគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងត្រូវដាក់ពាក្យសុំច្បាប់ឈប់សម្រាកពីការងារ រហូតដល់ថ្ងៃចប់ភារកិច្ច ។

**មាត្រា ៣៩.-**

ប្រធាន អនុប្រធាន លេខាធិការ និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវបាត់បង់ពីមុខតំណែងក្នុងករណីណាមួយ ដូចខាងក្រោម ៖

-សាមីខ្លួន ទទួលមរណភាព

-សាមីខ្លួន សុំលាឈប់ជាលាយលក្ខណ៍អក្សរ

-សាមីខ្លួន បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច

-សាមីខ្លួន ត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។

**មាត្រា ៤០.-**

ប្រធាន អនុប្រធាន លេខាធិការ និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោតត្រូវមានគណនេយ្យភាពតាមឋានានុក្រម ចំពោះមុខគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសិទ្ធិសម្រេចបណ្តេញប្រធាន អនុប្រធាន លេខាធិការ និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោតណាមួយ ក្នុងករណីប្រព្រឹត្តផ្ទុយពីច្បាប់ស្តីពីការបោះឆ្នោតជាធរមាន បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ឬក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចចេញសេចក្តីសម្រេចធ្វើប្រតិភូកម្មអំណាចជូនគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត តាមការចាំបាច់ ដើម្បីអនុវត្តបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រានេះ ។

**មាត្រា ៤១.-**

គណៈកម្មការការិយាល័យបោះឆ្នោតមានតួនាទីភារកិច្ច ដូចតទៅ ៖

១-អនុវត្តភារកិច្ចដែលច្បាប់ បទបញ្ជា នីតិវិធីនៃការបោះឆ្នោត និងលិខិតបទដ្ឋាននានាដែលបានអនុញ្ញាត ឬតម្រូវឲ្យអនុវត្ត ។

២-អនុវត្តភារកិច្ច និងសិទ្ធិដទៃទៀតដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រគល់ឲ្យ ។

# ជំពូកទី ៣
# ការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## ផ្នែកទី ១
## សមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

### មាត្រា ៤២.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសមត្ថកិច្ចក្នុងការធ្វើផែនការរៀបចំ និងចាត់ចែងការបោះឆ្នោតក្នុងទូទាំងប្រទេស ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិពេញលេញក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់នេះ ច្បាប់ស្តីពីការបោះឆ្នោតជាធរមាន បទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោតដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

សិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវទាក់ទងនឹងផែនការកម្ម ការរៀបចំ ការចាត់ចែង និងត្រួតពិនិត្យការបោះឆ្នោត មានដូចតទៅ ៖

១-ចាត់វិធានការគ្រប់រូបភាព ដើម្បីធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតាមវិធីជ្រើសរើសឆ្នោត ដោយសម្ងាត់ ។

២-រៀបចំគម្រោងផែនការការងារ ថវិកា និងសម្ភារបម្រើឲ្យការបោះឆ្នោត និងផ្សព្វផ្សាយប្រតិទិននៃការបោះឆ្នោត ។

៣-តែងតាំងគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត និងគណៈកម្មការការិយាល័យបោះឆ្នោត ។

៤-ធ្វើបទបញ្ញា នីតិវិធី និងសេចក្តីណែនាំនានាសម្រាប់ដំណើរការបោះឆ្នោត ក្នុងក្របខ័ណ្ឌនៃច្បាប់ជាធរមាន ។

៥-លើកវិធានការ និងចាត់ចែងការងារ ដើម្បីធានាកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងសម័យបោះឆ្នោត ។

៦-ត្រួតពិនិត្យការងាររបស់គណៈកម្មការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

៧-កំណត់ព្រំដែនការិយាល័យបោះឆ្នោត ។

៨-ចេញសេចក្តីសម្រេចកំណត់ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ។

៩-ផលិត និងបែងចែកសម្ភារ បរិក្ខារ បំរើឲ្យការងារបោះឆ្នោត ។

១០-ជ្រើសរើស និងតែងតាំងមន្ត្រីចុះជួយពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមច្បាប់ បទបញ្ញត្តិ និងនីតិវិធីសម្រាប់ការបោះឆ្នោត ។

១១- រៀបចំបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។

១២-ពិនិត្យ និងផ្តល់សុពលភាព បញ្ជីបោះឆ្នោត ។

១៣-ទទួល និងសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ស្របតាមច្បាប់បោះឆ្នោតជាធរមាន ។

១៤-គ្រប់គ្រង និងត្រួតពិនិត្យការប្រព្រឹត្តទៅនៃការឃោសនាបោះឆ្នោត ។

១៥-រៀបចំ និងចាត់ចែងការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផល និងការប្រកាសលទ្ធផល ។

១៦-ដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬផ្តល់សិទ្ធិបោះឆ្នោតឡើងវិញ ។

ចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬលុបចេញពីបញ្ជីឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ។

លុបបេក្ខភាពរបស់បេក្ខជនឈរឈ្មោះបោះឆ្នោត ឬទទួលស្គាល់បេក្ខភាពឈរឈ្មោះបោះឆ្នោតឡើងវិញ ។

១៧-ត្រួតពិនិត្យចំណូល និងចំណាយ ក្នុងរយៈពេលឃោសនាបោះឆ្នោតរបស់បេក្ខជន និងគណបក្សនយោបាយ ។

១៨-ចាត់វិធានការ និងសម្របសម្រួល ដើម្បីឲ្យមានការប្រើប្រាស់ប្រព័ន្ធឃោសនាសាធារណៈតាមគោលការណ៍ស្មើភាព និងសមធម៌ ។

១៩-ផ្តល់ព័ត៌មាន ទិន្នន័យ និងស្ថិតិអំពីដំណើរការបោះឆ្នោតដល់គណបក្សនយោបាយ និងបេក្ខជន និងទទួលសំណើនានាទាក់ទងនឹងការងារបោះឆ្នោត ។

ធានាឲ្យមានការផ្លាស់ប្តូរព័ត៌មាន និងការសម្របសម្រួលជាប្រចាំ អំពីកិច្ចដំណើរការបោះឆ្នោតរវាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាមួយគណបក្សនយោបាយ បេក្ខជន និងអ្នកដែលពាក់ព័ន្ធនានា ។

២០-ផលិតឯកសារផ្សព្វផ្សាយ អំពីការងារបោះឆ្នោត ។

២១-លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ អំពីការងារបោះឆ្នោត តាមរយៈការអប់រំ និងកម្មវិធីផ្សព្វផ្សាយជាសាធារណៈ និងដោយមធ្យោបាយផ្សេងៗទៀត ។

២២-រៀបចំឯកសារ កម្មវិធី និងបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុករៀបចំការបោះឆ្នោត ។

២៣-ពិនិត្យសម្រេច និងចេញប័ណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ។

២៤-ត្រួតពិនិត្យ ដើម្បីធានាភាពត្រឹមត្រូវតាមច្បាប់ បទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោត ។

២៥-សម្រេចដោយបើកសវនាការជាសាធារណៈលើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ទាក់ទងនឹងការបោះឆ្នោត ស្របតាមច្បាប់ បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោត លើកលែងតែបណ្តឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ ។

២៦-បង្ការ និងត្រួតពិនិត្យភាពមិនប្រក្រតីនៃការបោះឆ្នោត ។

២៧-រៀបចំគណៈកម្មការដើម្បីបំផ្លាញសន្លឹកឆ្នោត ដែលបានប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រតាមអាណត្តិនីមួយៗ បន្ទាប់ពីបានរក្សាទុកប្រកបដោយសុវត្ថិភាពនូវសន្លឹកឆ្នោតទាំងនោះរយៈពេល ០៦ (ប្រាំមួយ) ឆ្នាំ និងសន្លឹកឆ្នោតដែលបានប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់តាមអាណត្តិនីមួយៗ បន្ទាប់ពីបានរក្សាទុកប្រកបដោយសុវត្ថិភាពនូវសន្លឹកឆ្នោតទាំងនោះរយៈពេល ០៣ (បី) ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោតតាមអាណត្តិនីមួយៗ ។

ដំណើរការនៃការបំផ្លាញសន្លឹកឆ្នោតខាងលើនេះ ត្រូវធ្វើឡើងប្រកបដោយលក្ខណៈបើកចំហ និងមានការចូលរួមពីគណបក្សនយោបាយដែលពាក់ព័ន្ធ ។

២៨-អនុវត្តការងារដទៃទៀតតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា ៤៣.-**

ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវ ៖

១-ធានាថា សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងអស់ ត្រូវប្រតិបត្តិតាមច្បាប់ បទបញ្ជាផ្ទៃក្នុងរបស់ខ្លួន បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ព្រមទាំងក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត ។

២-កោះអញ្ជើញ និងដឹកនាំរាល់ការប្រជុំសាមញ្ញ និងការប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

៣-ជាតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅក្នុងការទំនាក់ទំនងជាមួយព្រះមហាក្សត្រ ស្ថាប័ននានា អង្គការជាតិ និងអង្គការអន្តរជាតិ ។

៤-ជូនរបាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទៅរដ្ឋសភា និងព្រឹទ្ធសភា ។

៥-ចុះហត្ថលេខាលើគ្រប់ឯកសារផ្លូវការ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៤៤.-**

អនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជួយធ្វើការប្រធានទៅតាមការបែងចែកភារកិច្ចពីប្រធាន ។ កាលបើប្រធានអវត្តមាន ឬមកធ្វើការពុំបាន អនុប្រធានធ្វើការជួសប្រធាន ក្នុងឋានៈជាប្រធានស្តីទី តាមរយៈលិខិតផ្ទេរសិទ្ធិ ។

ROYAUME DU CAMBODGE • LE MINISTRE du PALAIS ROYAL

**មាត្រា ៤៥.-**

សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលភារកិច្ចតាមការកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុង និងតាមការប្រគល់ភារកិច្ចពីប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៤៦.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចចេញសេចក្តីសម្រេចប្រគល់សិទ្ធិរបស់ខ្លួនដល់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត គណៈកម្មការការិយាល័យបោះឆ្នោត និងមន្ត្រី ឬភ្នាក់ងារបម្រើការងារបោះឆ្នោត ដើម្បីអនុវត្តការងារបោះឆ្នោត ។

**មាត្រា ៤៧.-**

ប្រាក់បំណាច់ និងប្រាក់កម្រៃសម្រាប់សមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## ផ្នែកទី ២
## របៀបរបបការងាររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**មាត្រា ៤៨.-**

របៀបរបបធ្វើការងាររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងដែលរៀបចំ និងអនុម័តដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៤៩.-**

បទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងច្បាប់ស្តីពីការបោះឆ្នោតជាធរមាន បន្ទាប់ពីចូលកាន់តំណែង ។

**មាត្រា ៥០.-**

ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាអ្នកកោះប្រជុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្នុងករណីដែលសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មិនបានចូលរួមប្រជុំ ឬអវត្តមាន ដោយគ្មានមូលហេតុតាមការកោះប្រជុំចាប់ពី ០៣ (បី) ដងឡើងទៅ សមាជិកនោះ ត្រូវចាត់ទុកថា បោះបង់មុខតំណែង ។

សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមួយភាគបី (១/៣) មានសិទ្ធិស្នើជា លាយលក្ខណ៍អក្សរ ដោយភ្ជាប់ជាមួយរបៀបវារៈ ឬកម្មវត្ថុជាក់លាក់ទៅប្រធានគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ដើម្បីកោះប្រជុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយប្រធានគណៈ - កម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកោះប្រជុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ការប្រជុំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចយកជាការបាន លុះត្រាតែមាន ៖

-កូរ៉ុមពីរភាគបី (២/៣) នៃចំនួនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងមូល សម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឲ្យយកមតិភាគច្រើន ពីរភាគបី (២/៣) នៃចំនួន សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងមូល ។

-កូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំង មូលសម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឲ្យយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងមូល ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអនុម័តសម្រេចបទបញ្ជាផ្ទៃក្នុង និងបទបញ្ជា និង នីតិវិធីសម្រាប់ការបោះឆ្នោត ដោយសំឡេងពីរភាគបី (២/៣) នៃចំនួនសមាជិកគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោតទាំងមូល ។ ករណីមិនមានកូរ៉ុម ឬ/និងសំឡេងគ្រប់ចំនួនសម្រាប់អនុម័តតាម មតិភាគច្រើន ពីរភាគបី (២/៣) នៃចំនួនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងមូល ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើការកោះប្រជុំជាលើកទី ២ នៅថ្ងៃបន្ទាប់ជា បន្ទាន់ ហើយកូរ៉ុម និងសំឡេងសម្រាប់អនុម័ត ត្រូវមានចំនួនភាគច្រើនដាច់ខាតនៃសមាជិកគណៈ - កម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងមូល ។

ក្រៅពីបទបញ្ជាផ្ទៃក្នុង និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំ ការបោះឆ្នោតត្រូវអនុម័តសម្រេច ដោយសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកគណៈកម្មាធិការ ជាតិរៀបចំការបោះឆ្នោតទាំងមូល ។

ករណីមានសំឡេងស្មើគ្នាក្នុងការអនុម័តលើបញ្ហាណាមួយ សំឡេងរបស់ប្រធានគណៈកម្មាធិការ ជាតិរៀបចំការបោះឆ្នោត មានឧត្តមានុភាព ។

ក្នុងករណីដំណើរការរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវជាប់គាំងដោយសារ មិនមានកូរ៉ុម ឬមិនមានសំឡេងគ្រប់គ្រាន់ ដើម្បីអនុម័តបញ្ហាណាមួយ រដ្ឋសភាត្រូវធ្វើការសម្រេច រំលាយសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានបញ្ហានោះ ហើយត្រូវរៀបចំ សមាសភាពថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៥១.-**

រាល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផ្សព្វផ្សាយជាសាធារណៈ ក្នុងរយៈពេលយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីការធ្វើសេចក្តីសម្រេច ។

## ផ្នែកទី ៣
## អគ្គលេខាធិការដ្ឋាន

**មាត្រា ៥២.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ ។

អគ្គលេខាធិការ អគ្គលេខាធិការរង និងមន្ត្រី បុគ្គលិកទាំងអស់ ត្រូវមានគណនេយ្យភាពតាមឋានានុក្រមចំពោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៥៣.-**

អគ្គលេខាធិការដ្ឋានត្រូវដឹកនាំដោយអគ្គលេខាធិការមួយ (០១) រូប និងអគ្គលេខាធិការរងមួយចំនួនជាជំនួយការ ។

**មាត្រា ៥៤.-**

អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវមានលក្ខណសម្បត្តិ ដូចខាងក្រោម ៖

-មានសញ្ជាតិខ្មែរពីកំណើត និងមានសញ្ជាតិខ្មែរតែមួយគត់ ក្នុងរយៈពេលបំពេញការងារ

-មានអាយុយ៉ាងតិច ៣០ (សាមសិប) ឆ្នាំ គិតដល់ថ្ងៃតែងតាំង

-មានសិទ្ធិបោះឆ្នោត

-មានសញ្ញាបត្រចាប់ពីថ្នាក់ឧត្តមសិក្សាឡើងទៅ

-មានបទពិសោធន៍ការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ

-មិនត្រូវជាសហព័ទ្ធ ឬញាតិលោហិត ឬញាតិពន្ធរហូតដល់ថ្នាក់ទី ៣ របស់ប្រធាន អនុប្រធានគណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត ។

**មាត្រា ៥៥.-**

អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ទាប់ពីបានយោបល់យល់ស្របតាមសម្លេងភាគច្រើនដាច់ខាតនៃសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងមូល ។

អគ្គលេខាធិការត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើនឹងរដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន ។

អគ្គលេខាធិការរងត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើនឹងអនុរដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន ។

មន្ត្រី បុគ្គលិកនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងនៃលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត គឺជាមន្ត្រី បុគ្គលិក ស្ថិតក្នុងក្របខ័ណ្ឌនៃលក្ខន្តិកៈដោយឡែកមួយ ដែលកំណត់ដោយព្រះរាជក្រឹត្យ តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ទាប់ពីមានយោបល់ឯកភាពពីក្រសួងមុខងារសាធារណៈ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ដើម្បីបម្រើការងារតាមការចាំបាច់ ។

**មាត្រា ៥៦.-**

អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវបាត់បង់មុខតំណែង ក្នុងករណីណាមួយ ដូចខាងក្រោម ៖

-សាមីខ្លួន ទទួលមរណភាព

-សាមីខ្លួន សុំលាឈប់ជាលាយលក្ខណ៍អក្សរ

-សាមីខ្លួន បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច

-សាមីខ្លួន ត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។

**មាត្រា ៥៧.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## ជំពូកទី ៤
## ថវិការបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**មាត្រា ៥៨.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានថវិកាស្វយ័តសម្រាប់ដំណើរការ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់ចែង និងប្រើប្រាស់ថវិកាសម្រាប់កិច្ចការបោះឆ្នោត ប្រកបដោយតម្លាភាព សុចរិតភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

**មាត្រា ៥៩.-**

ត្រូវបានបង្កើតគណនីពិសេសរបស់រតនាគារជាតិ ជាគណនីមូលនិធិទាយជ្ជទានការបោះឆ្នោត សម្រាប់ឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យកទៅចាត់ចែងក្នុងកិច្ចការបោះឆ្នោត ។

មូលនិធិទាយជ្ជទានការបោះឆ្នោត ដែលបានមកពីភាគទានផ្សេងៗរបស់រាជរដ្ឋាភិបាល ជំនួយរបស់រដ្ឋាភិបាលបរទេស អង្គការអន្តរជាតិនានា អំណោយពីសប្បុរសជន អំណោយពីអង្គការក្រៅរដ្ឋាភិបាល និងចំណូលស្របច្បាប់ផ្សេងៗ ត្រូវបញ្ចូលក្នុងថវិកាជាតិ ដើម្បីផ្តល់ផ្ទាល់ឲ្យទៅគណនីពិសេសនេះ ។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

**មាត្រា ៦០.-**

សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងបទវិន័យ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។ បទវិន័យនេះ ត្រូវកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## ជំពូកទី ៦
## អន្តរប្បញ្ញត្តិ

**មាត្រា ៦១.-**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបច្ចុប្បន្ន ត្រូវបន្តបំពេញការងាររហូតដល់មានប្រធាន អនុប្រធាន និងសមាជិក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលត្រូវបានតែងតាំងស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ចូលកាន់មុខតំណែង ។

**មាត្រា ៦២.-**

សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលត្រូវបង្កើតឡើងស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ មានអាណត្តិរហូតដល់មានការតែងតាំងជាថ្មីនូវប្រធាន អនុប្រធាន និងសមាជិកគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត ស្របតាមកថាខណ្ឌទី ៥ នៃមាត្រា ៦ នៃច្បាប់នេះ ។

**មាត្រា ៦៣.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលត្រូវបានបង្កើតឡើងស្របតាមបទប្បញ្ញត្តិ នៃច្បាប់នេះ ត្រូវបំពេញការងារ ដោយផ្អែកតាមច្បាប់ បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងលិខិតបទដ្ឋានដែលមានជាធរមានរហូតដល់មានបទប្បញ្ញត្តិថ្មីមកជំនួស ។

**មាត្រា ៦៤.-**

អគ្គលេខាធិការ អគ្គលេខាធិការរង មន្ត្រី បុគ្គលិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបន្តការងារជាអគ្គលេខាធិការ អគ្គលេខាធិការរង មន្ត្រី បុគ្គលិកនៃគណៈកម្មាធិការជាតិរៀបចំការ

បោះឆ្នោត ដែលបានរៀបចំឡើងតាមច្បាប់នេះ រហូតដល់មានការតែងតាំងថ្មី ស្របតាមច្បាប់នេះ ។

ការផ្លាស់ប្តូរ និងតែងតាំងអគ្គលេខាធិការ អគ្គលេខាធិការរង មន្ត្រី បុគ្គលិក នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើឡើងដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

មន្ត្រី បុគ្គលិកដែលកំពុងបម្រើការងារក្នុងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវបានធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌនៃលក្ខន្តិកៈដោយឡែក ដូចមានចែងក្នុងកថាខណ្ឌទី ៤ នៃមាត្រា ៥៥ នៃច្បាប់នេះ ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**មាត្រា ៦៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ និងត្រូវជំនួសដោយច្បាប់នេះ ។

**មាត្រា ៦៦.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១៥

ចាស. ១៥០៣.២៣៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខៈ ២៥៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី២៧ ខែ មីនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២០៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្ទេរក្របខ័ណ្ឌឯកឧត្តម **ទ៉ា ឈូជា** ពីឋានន្តរស័ក្តិវរៈមន្ត្រីថ្នាក់លេខ ៧ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មកក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា២ :** តែងតាំងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនឯកឧត្តម **ទ៉ា ឈូជា** អត្តលេខ **៧៣៦០៦** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ពរល.១៥០៣.២០៩

លេខ: ២៣៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២១៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

អ្នកគ្រូ **នាង ផល្លា**

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសបន្ទាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខ: ២៧៣៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ០៣ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៣រល.១៥០៣.២១៧

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

១- ព្រះតេជគុណ ខៀវ អឿន
២- ព្រះតេជគុណ ខៀវ សំអាង
៣- ព្រះតេជគុណ ឈាង ឆយ
៤- ព្រះតេជគុណ ឡូច ម៉ៃ
៥- ព្រះតេជគុណ គីម ឆួង

ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍

១- សម្តេចព្រះមហាអរិយវង្ស សៅរ៍ ចន្ទថុល្ល
២- ព្រះតេជគុណ ញ៉ៀម គីមគេង
៣- ព្រះតេជគុណ ឈឿន ភន់
៤- ព្រះតេជគុណ សម ហាយ
៥- ព្រះតេជគុណ ចា ណឹម
៦- ព្រះតេជគុណ សែម ប៊ុច
៧- ព្រះតេជគុណ ម៉ក់ សុខន
៨- លោក ផន ដាវី

*ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែ មីនា ឆ្នាំ ២០១៥*

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ពរល.១៥០៣.២១៩

លេខៈ ៧៤៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២១៤

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១- ព្រះបារមីធម្មបាល **ស៊ិន សោភ័ណ**
២- ព្រះមហាខេមបាលោ **អ៊ើម ស៊ីង**
៣- លោក **តាន់ តៃថ្វាន់**

ខ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១- ឧកញ៉ា **ហេង សំណាង**
២- វរសេនីយ៍ត្រី **យ៉េង សារ៉េន**

គ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

១- ព្រះតេជគុណ **គង ឈន**
២- ព្រះតេជគុណ **គង ស៊ីង**
៣- ព្រះតេជគុណ **ឡុង ប៊ុនធឿន**
៤- ព្រះតេជគុណ **ជាំ សុវណ្ណាការ**
៥- លោក **កុច ស៊ុនហួរ**
៦- លោក **គង់ គេង**
៧- លោក **យី លីមដាវ**
៨- លោក **ប៉ែន សុផាត**
៩- លោក **សៀង ជីសេង**
១០- លោក **ដេត មាំងផុង**

ឃ- គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរត្ន** ថ្នាក់ **មហាសេនា**

១- ព្រះមហា **ហាយ សុរហ៊ីម**
២- ព្រះមហា **ស្រី សុំ**

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ជ.រស.១៥០៣.២១៩

លេខៈ ២៤៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ០៣ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២១៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ដំឡើងឋានៈឯកឧត្តម **ជុង ហ៊ន់ទូ** ទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី៣ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខ: ៤៣៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ៣ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៣៧៦.១៥០៣.២២០

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២២០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១ :** តែងតាំងឯកឧត្តម **ឈិន យ៉ុងសៀង** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី៣ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៧រល.១៥០៣.២២១

លេខ:២៣៩.ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ៣ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២២១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម**
ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា )

**ត្រាស់បង្គាប់**

**តែងតាំង :**

លោកស្រី **ស៊ុំ ហៀង**

ជា

**ឧកញ៉ា**

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ចករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ចរស.១៥០៣.២២២

លេខ: ២៨១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ៣ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៧២

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**
ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ព្រះតេជគុណព្រះមហា **អេង ផល្លា**
២- ព្រះតេជគុណព្រះមហា **អ៊ិន ធារី**
៣- ឯកឧត្តមវេជ្ជបណ្ឌិត **តាន់ សុគុន**
៤- ឯកឧត្តម **ហួន សារឿន**
៥- ឯកឧត្តម **គីម ឈួន**
៦- ឯកឧត្តមវេជ្ជបណ្ឌិត **ទូច សុក្រិត**
៧- ឯកឧត្តម **លីម ហួរ**
៨- ឯកឧត្តម **សុខុម វីរផល**
៩- ឯកឧត្តម **សេក សុខឃឿន**
១០- ឯកឧត្តម **ឯក សុនសត្យា**
១១- ឯកឧត្តម **ឈួន សម្បត្តិ**
១២- លោកជំទាវ **សំអាង ពិសីសិទ្ធ**
១៣- លោកជំទាវ **ផេង សុខា**
១៤- ឧត្តមសេនីយ៍ទោ **ឈឹម សុផាណារ៉ាត**
១៥- ឧត្តមសេនីយ៍ត្រី **គិត សុផល**
១៦- ឧត្តមសេនីយ៍ត្រី **គីម សារី**
១៧- ឧត្តមសេនីយ៍ត្រី **ស៊ូ វិរៈ**
១៨- ឧត្តមសេនីយ៍ត្រី **ខៀវ គាវុធ**
២៧- វរសេនីយ៍ទោ **ជិន ជា**
២៨- វរសេនីយ៍ទោ **ស៊ុំ អាន**
២៩- វរសេនីយ៍ទោ **ម៉ី ចាន់ដារ៉ា**
៣០- វរសេនីយ៍ត្រី **ចាន់ វិទូ**
៣១- វរសេនីយ៍ត្រី **តាំង វ៉េង**
៣២- វរសេនីយ៍ត្រី **មាស សុភ័ក្រ**
៣៣- អនុសេនីយ៍ឯក **ញឹក ស៊ីណាត**
៣៤- អនុសេនីយ៍ឯក **សៅ លឿត**
៣៥- អនុសេនីយ៍ទោ **គីម សុធី**
៣៦- លោក **អ៊ុត វ៉ូហ្សា**
៣៧- លោកស្រី **គីម ហោ**
៣៨- លោក **ទុំ សុផាត**
៣៩- លោកស្រី **លឹម គៀន**
៤០- លោក **ស៊ិន ឌីដេនីន**
៤១- លោក **ឈន សុគន្ធ**
៤២- លោក **ឌួង សុជាតិ**
៤៣- លោក **ប៉ុញ លេនីន**
៤៤- លោក **ថាត់ សុវណ្ណា**

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

១៩- វរសេនីយ៍ឯក **តឹង ចិន្តាឫទ្ធិ**
២០- វរសេនីយ៍ឯក **សុខ លី**
២១- វរសេនីយ៍ឯក **ទ្រូក តាន**
២២- វរសេនីយ៍ឯក **លឹម ផេង**
២៣- វរសេនីយ៍ឯក **តូច សុគន្ធ**
២៤- វរសេនីយ៍ទោ **យឹម សុផារណាវី**
២៥- វរសេនីយ៍ទោ **សួន បូណា**
២៦- វរសេនីយ៍ទោ **ប្រាក់ ប៊ុណា**
៤៥- លោក **ឡេង គីឈ័ង**
៤៦- លោក **ប៊ូ ជុំផល្លា**
៤៧- លោក **សេក ស៊ុនវ៉ាន់ឌី**
៤៨- លោក **ចាន់ សុវណ្ណឌី**
៤៩- លោក **ហេង ប៊ុនធឿន**
៥០- លោក **អ៊ុល ប៊ុណ្ណា**
៥១- លោក **ចឹយ វិចិត្ត**
៥២- លោក **ងួន ឡាញ់**

ខ- គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

១- ឯកឧត្តម **ឈឿង ផល្លាង**
២- ឯកឧត្តម **ធន វិមានច័ន្ទ**
៣- វរសេនីយ៍ឯក **ចាន់ អូន**
៤- លោក **ទី ប៊ុនឡេង**
៥- លោក **អ៊ុត រាជ្យ**
៦- លោក **សេង ម៉េងហេង**
៧- លោកស្រី **ទីវ ម៉េងលីម**
៨- លោក **គាង អ៊ាង**
៩- លោក **ពុធ វាសនា**
១០- លោក **គុណ សុគ័ណ្ឌ**
១១- លោកស្រី **គឹម បូរ៉ាវី**
១២- លោក **សៀ ម៉ាប់**

គ- គ្រឿងឥស្សរិយយស **មុន្នីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

១- ឧត្តមសេនីយ៍ទោ **ចេង ហុង**
២- ឯកឧត្តម **សួង ណាយ**
៣- លោក **គង់ សម្បូរ**
៤- វរសេនីយ៍ឯក **ហ៊ង បូរិទ្ធ**
៥- វរសេនីយ៍ទោ **ជួង តន**
៦- លោក **មុយ ឆាយ**

ឃ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

១- ឧត្តមសេនីយ៍ទោ **ទៀប ហ៊ន**
២- ឯកឧត្តម **លន់ មុនីរតនា**
៣- វរសេនីយ៍ទោ **ហាក់ សុវណ្ណ**
៤- វរសេនីយ៍ទោ **ជ្រឹន ហាច**
៥- វរសេនីយ៍ត្រី **ស្រី សំអុល**
៦- វរសេនីយ៍ត្រី **ទូច ពិនតារា**
៧- វរសេនីយ៍ត្រី **សារុន សំអឿន**
៨- លោក **គឹម សុភារៈ**
៩- លោក **វ៉ា ម៉ៅ**
១០- លោក **ខែក ពិសិដ្ឋ**
១១- លោក **អ៊ុច រ៉ាស៊ី**

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា :**

១- ព្រះតេជគុណព្រះមហា **ចាន់ ប៊ុនធឿន**
២- ព្រះតេជគុណ **គង សុខ**
៣- ព្រះតេជគុណ **ទ៉ូវ ជិន**
៤- វរសេនីយ៍ឯក **វ៉ា រិទ្ធី**
៥- វរសេនីយ៍ឯក **លឹម ហួរ**
៦- វរសេនីយ៍ឯក **ស៊ូ សុង**
៧- វរសេនីយ៍ទោ **ស្រ៊ុន ឌីកឡេង**
៨- វរសេនីយ៍ទោ **យិន ស៊ាត**
៩- វរសេនីយ៍ទោ **ចេង សុវណ្ណារិទ្ធ**
២៩- វរសេនីយ៍ត្រី **សរ កុសល**
៣០- វរសេនីយ៍ត្រី **ជឹម ចាន់រ៉ា**
៣១- វរសេនីយ៍ត្រី **ញឹក ចាន់កុសល**
៣២- វរសេនីយ៍ត្រី **ម៉ាង និមល**
៣៣- វរសេនីយ៍ត្រី **លឹម ឆាយ**
៣៤- អនុសេនីយ៍ទោ **អូន ច័ន្ទសុធារិទ្ធ**
៣៥- លោក **លឹម គាងតុង**
៣៦- លោក **ប្រាក់ ផានិត**
៣៧- លោក **ហេង គីមហាយ**

១០- វរសេនីយ៍ទោ **ឡាំ លី**
១១- វរសេនីយ៍ទោ **ភន សុគឿន**
១២- វរសេនីយ៍ទោ **អឿង សារ៉ាត**
១៣- វេជ្ជបណ្ឌិត **ជ្រឿ សុខលាង**
១៤- លោក **នី វ៉ូហ្សា**
១៥- លោក **ជា ហេង**
១៦- លោក **ម៉ាន់ សំអឿន**
១៧- លោក **នុត យន**
១៨- លោក **ផល ឈុនហេង**
១៩- លោក **ឌី មន្ទីរត**
២០- លោក **យូ វណ្ណារ៉ា**
២១- លោក **សេង សុឡារ៉ា**
២២- លោក **ដួង បុណ្ណ**
២៣- លោក **ឡាំង ម៉ុនយន**
២៤- លោក **ព្រុំ វិសេស**
២៥- លោក **សៅ សឿន**
២៦- លោក **ម៉ុ សុខារត្ន៍**
២៧- លោក **វ៉ាន់ វាសនា**
២៨- លោកស្រី **លឹម សាមាន**
៣៨- លោក **ចេង គីមជប់**
៣៩- លោក **ធីម សាងឡេង**
៤០- លោក **ប៊ូ ហេង**
៤១- លោក **នួន ឌឿន**
៤២- លោក **គឹម អាង**
៤៣- លោកស្រី **ផេង សុខា**
៤៤- លោក **ឈិត សុខជា**
៤៥- លោក **សែម ធីរូ**
៤៦- លោក **ចិន ឡាធី**
៤៧- លោក **លាត រដ្ឋា**
៤៨- លោក **ម៉ាន់ នីរក្ស**
៤៩- លោក **ប្រាក់ ដារ៉ា**
៥០- លោក **ជុំ សុខហ៊ាន**
៥១- លោក **សរ បូរ៉ាន់**
៥២- លោក **ជុំ រ៉ាវុធ**
៥៣- លោក **សាង វុឌ្ឍី**
៥៤- លោក **រស់ សារិន**
៥៥- លោក **ឆាយ សុគន្ធជា**

ច- គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្ន** ថ្នាក់ **មហាសេនា :**

១- លោកជំទាវ **ស៊ន ឌីធីតា**
២- លោកជំទាវ **ហួ ចាន់ស៊ី**

ឆ- គ្រឿងឥស្សរិយយស **មុន្នីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា :**

១- ឯកឧត្តម **ហោ ត្រៃ**
២- វរសេនីយ៍ឯក **ព្រាប សុខ**
៣- វរសេនីយ៍ឯក **មាស សម្បត្តិ**
៤- វរសេនីយ៍ឯក **ញៀម វិរះដួប**
៥- វរសេនីយ៍ឯក **សោម ម៉ុនហេង**
៦- វរសេនីយ៍ឯក **សាន់ ម៉ុនណា**
៧- អនុសេនីយ៍ត្រី **ចាន់ បូរី**
៨- លោក **សុធី សុវិត្យា**
៩- លោក **សុខ ជីសេង**
១០- លោក **ថៃ ទ្រី**

ជ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា :**

១- ឧត្តមសេនីយ៍ត្រី **សុខ សារ៉ន**
២- ឧត្តមសេនីយ៍ត្រី **ប៉ុល ខុន**
៣- ឧត្តមសេនីយ៍ត្រី **តូច វាសនា**
៤- ឧត្តមសេនីយ៍ត្រី **ទឹម សម្បត្តិ**
៥- វរសេនីយ៍ឯក **អ៊ុង សុខណា**
៦- អនុសេនីយ៍ឯក **អ៊ុច ស៊ីម៉ារ៉ូ**
៧- លោក **ហ៊ុយ ជីវិត**
៨- លោក **សូ ដានី**

ឈ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ :**

១- វរសេនីយ៍ទោ **ពុត ឡៃហេង**
២- វរសេនីយ៍ទោ **ចេន ហ៊ុច**
២២- លោក **សេង សាគល់**
២៣- លោក **អៃ សុវុធ**

៣- វរសេនីយ៍ទោ **ជួន ផលលី**
៤- វរសេនីយ៍ត្រី **សន ខន**
៥- វរសេនីយ៍ត្រី **អ៊ុន សារិន**
៦- វរសេនីយ៍ត្រី **ស៊ុក គន្ធណារ៉ុង**
៧- វរសេនីយ៍ត្រី **ម៉ែន សំណាង**
៨- វរសេនីយ៍ត្រី **ឆន់ សុភាព**
៩- វរសេនីយ៍ត្រី **ប៊ុល សុភា**
១០- វរសេនីយ៍ត្រី **ជា សុភាព**
១១- វរសេនីយ៍ត្រី **ឯម នី**
១២- វរសេនីយ៍ត្រី **ស្រី ម៉ៅ**
១៣- វរសេនីយ៍ត្រី **ហុង នីភូលីន**
១៤- វរសេនីយ៍ត្រី **ម៉ែន សុភក្តិ**
១៥- អនុសេនីយ៍ឯក **អ៊ុំ សុខុមជារ៉ា**
១៦- អនុសេនីយ៍ឯក **ឈឺន នឿម**
១៧- លោក **ស្រេង សារតារ៉ូ**
១៨- លោក **ព្រុំ លាភី**
១៩- លោក **កែ កឿន**
២០- កញ្ញា **លីម រស្មី**
២១- លោក **គីម ម៉ា**
២៤- លោកស្រី **ចាន់ កិត្យា**
២៥- លោក **ខាត់ ឧុនតារាផល**
២៦- លោក **ស្វ សារ៉េត**
២៧- លោក **ជីវ គីមអ៊ុន**
២៨- លោក **ម៉ែន ផល្គុន**
២៩- លោក **ឡឹម តារា**
៣០- លោក **ជួន ម៉ារឌី**
៣១- លោក **ឡេង ជួន**
៣២- លោក **នុត សុខសៅរិទ្ធី**
៣៣- លោក **ជា អឿម**
៣៤- លោក **ហ៊ុន សេដ្ឋា**
៣៥- លោក **សុខ សារ៉ូម**
៣៦- លោក **នាក់ មីនា**
៣៧- លោក **ពៅ សួងហួរ**
៣៨- លោក **ម៉ៅ សុវណ្ណា**
៣៩- លោកស្រី **ខៀវ ធីតា**
៤០- លោក **សៅ សម្ភារ**
៤១- លោក **ប៉ែត សារ៉ាត់**
៤២- កញ្ញា **ហែម សុហ៊ីយ៉ា**

ញ- គ្រឿងឥស្សរិយយស **មុន្នីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** :

១- លោក **ចំរើន រស្មី**
២- លោក **ឥន សុភាព**

ដ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

១- វរសេនីយ៍ឯក **សុខ លាង**
២- វរសេនីយ៍ទោ **ភាន់ ពេញ**
៣- វរសេនីយ៍ត្រី **ឡុង សារ៉ាត់**
៤- អនុសេនីយ៍ឯក **ស៊ុន សុវណ្ណា**
៥- អនុសេនីយ៍ឯក **នង ស៊ីម៉ី**
៦- អនុសេនីយ៍ឯក **ហ៊ាន សឿន**
៧- អនុសេនីយ៍ឯក **ម៉ុន ណារុប**
៨- អនុសេនីយ៍ត្រី **ហួត ឌី**
៩- កញ្ញា **យ៉េន សោម៉ានី**
១០- លោកស្រី **អ៊ុំ នាងទូច**
១១- វេជ្ជបណ្ឌិត **ចាន់ សុបុណ្ណារិទ្ធ**
១២- វេជ្ជបណ្ឌិត **សរ ចាន់រស្មី**
១៣- វេជ្ជបណ្ឌិត **ឈុន គីរីវាត**
១៤- នាយចំណង់ **ហេង សុម៉ារ៉ា**
១៥- លោក **សុខ ប៊ុនធីរៈ**
១៦- លោក **ស៊ុំ សីហា**
១៧- វេជ្ជបណ្ឌិត **ជួប សម្បត្តិ**
១៨- លោក **អ៊ុំ ឈាងអេង**
១៩- លោក **យឹម សុម៉ារិទ្ធ**
២០- លោកស្រី **សេង ហុយស៊ីម**
២១- លោក **រ័ត្ន ចន្ថា**
២២- លោកស្រី **ស៊ិន ឌីដេលីន**
២៣- វេជ្ជបណ្ឌិត **ហ៊ាន សុខនាង**
២៤- វេជ្ជបណ្ឌិត **ណារុប ប៊ុនធា**
២៥- វេជ្ជបណ្ឌិត **នាម លាងឈីម**

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ផ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ :**

១- វរសេនីយ៍ទោ **ឈិត សុវណ្ណ**
២- វរសេនីយ៍ត្រី **ជា ណេន**
៣- វរសេនីយ៍ត្រី **ជាង គីមសែ**
៤- អនុសេនីយ៍ឯក **ទ៉ា ខ្លា**
៥- អនុសេនីយ៍ទោ **តែ ហេងយី**
៦- អនុសេនីយ៍ទោ **ពេជ្រ ចាន់ធឿន**
៧- អនុសេនីយ៍ទោ **ស៊ូ ស៊ុងប៊ុន**
៨- អនុសេនីយ៍ត្រី **ផាត រិន**
៩- អនុសេនីយ៍ត្រី **ចៅ តឿន**
១០- Mr. AU YEUNG CHUN HIM
១១- ព្រឹទ្ធបាលឯក **សួង សិទ្ធ**
១២- លោក **នៅ ចាន់ធី**
១៣- កញ្ញា **គិន ស្រីដា**
១៤- លោក **នៅ ចាន់សុគា**
១៥- កញ្ញា **អិន សុម៉ាលក្ខ**
១៦- កញ្ញា **ហេង បុប្ផារ័ត្ន**
១៧- កញ្ញា **យី សុជីតា**
១៨- លោក **ជា ចក**
១៩- លោក **គួ ស៊ិងអ៊ី**
២០- Mrs. LIANG YEN CHIA

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ចរស.១៥០៣.២២៣

លេខៈ ២៤៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២២៣

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តមឧត្តមសេនីយ៍ឯក **ណុប ទី** អត្តលេខ ០១១៨៨ ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៧រស.១៥០៣.២២៤

លេខ:២៣៣ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/ ២២៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **ឈឹម សំអាត** ជាទីប្រឹក្សាអមក្រសួងផែនការ មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខ: ៧៣២ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៣រស.១៥០៣.២២៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ២៥៤/០០១/២០១៥
ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥

**សេចក្តីសម្រេច**
លេខ : ១៥៣/០០១/២០១៥ កបធ.ច
ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ២៦១ រ.ស ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៦ នីតិកាលទី៣ នាថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ វេលាម៉ោង ១១ និង ៣០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញក្នុងការពិនិត្យនិងអនុម័តច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះ មកពិនិត្យបាន

- យល់ឃើញថា ទម្រង់នៃការតាក់តែង និងការអនុម័តច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅមាន ៣មាត្រា គឺពីមាត្រា១ ដល់មាត្រា៣ ដែលចែងពីគោលដៅ ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឈ្មោះជាអក្សរកាត់ "គ.ជ.ប" រចនាសម្ព័ន្ធ ការអនុវត្តសមត្ថកិច្ចដោយឯករាជ្យនិងអព្យាក្រឹត ដើម្បីធានាឱ្យការបោះឆ្នោតទាំងអស់ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ត្រូវមានជំហរអព្យាក្រឹតឥតលម្អៀងក្នុងការអនុវត្តការងារបោះឆ្នោត។ បទប្បញ្ញត្តិក្នុងមាត្រាទាំង៣នៃជំពូកទី១នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី២ ស្តីពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចែកចេញជា៤ផ្នែក និងមាន ៣៨មាត្រា គឺពីមាត្រា៤ ដល់មាត្រា៤១

-ផ្នែកទី១ ចែងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមាសភាព ៩រូប ប្រធាន ១រូប អនុប្រធាន ១រូប និងសមាជិក ៧រូប បោះឆ្នោតជ្រើសតាំងដោយរដ្ឋសភា និងមានអាណត្តិ ៥ឆ្នាំ។ លក្ខណសម្បត្តិសម្រាប់ជ្រើសរើស បែបបទនិងនីតិវិធី ឋានៈ បុព្វសិទ្ធិ វិសមិតភាព ការបាត់បង់មុខតំណែងក៏ត្រូវបានកំណត់ក្នុងផ្នែកទី១ នេះដែរ

-ផ្នែកទី២ ស្តីពីការរៀបចំគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតមាន១២មាត្រា គឺពីមាត្រា១៤ ដល់មាត្រា២៥ ចែងពីសមាសភាពមានប្រធាន ១រូប អនុប្រធាន ១រូប និង សមាជិក ៣ ឬ ៥រូប ឋានៈ បុព្វសិទ្ធិ លក្ខខណ្ឌ តួនាទីភារកិច្ច និងការទទួលខុសត្រូវនៅចំពោះមុខគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងមានលេខាធិការដ្ឋានធានានិរន្តរភាពរបស់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត

-ផ្នែកទី៣ ស្តីពីការរៀបចំគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតមាន៨មាត្រា គឺពីមាត្រា២៦ ដល់មាត្រា៣៣ ចែងពីសមាសភាពរបស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតដែលមានប្រធាន ១រូប អនុប្រធាន ១រូប សមាជិក ៣ ឬ ៥រូប ទទួលខុសត្រូវចំពោះមុខគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-ផ្នែកទី៤ ស្ដីពីការរៀបចំគណៈកម្មការការិយាល័យបោះឆ្នោតមាន ៨មាត្រា គឺពីមាត្រា៣៤ ដល់មាត្រា៤១ មានសមាសភាពប្រធាន ១រូប អនុប្រធាន ១រូប លេខាធិការ ១រូប និងសមាជិក ៧រូប ទទួលខុសត្រូវចំពោះមុខគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ បទប្បញ្ញត្តិក្នុងមាត្រាទាំង៣៨នៃជំពូកទី២នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៣ ស្ដីពីការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចែកចេញជា៣ ផ្នែក និងមាន ១៦មាត្រា គឺពីមាត្រា៤២ ដល់មាត្រា៥៧

-ផ្នែកទី១ ស្ដីពីសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមាន ២៨ ចំណុច ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានភារកិច្ច ៩ចំណុច អនុប្រធានជួយធ្វើការប្រធានតាមការបែងចែកភារកិច្ចពីប្រធាន និង ជំនួសប្រធានពេលប្រធានអវត្តមាន ឬមកធ្វើការពុំបានក្នុងឋានៈជាប្រធានស្ដីទីតាមលិខិតផ្ទេរសិទ្ធិ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិកំណត់ប្រាក់បំណាច់ និងប្រាក់កម្រៃផ្សេងៗដល់សមាជិក មន្ត្រី បុគ្គលិកថ្នាក់ក្រោម

-ផ្នែកទី២ ស្ដីពីរបៀបរបបការងាររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមាន៤មាត្រា គឺពីមាត្រា៤៨ ដល់មាត្រា៥១

-ផ្នែកទី៣ ស្ដីពីអគ្គលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមាន៦មាត្រា គឺពីមាត្រា៥២ដល់មាត្រា៥៧។ មន្ត្រី បុគ្គលិកនៃអគ្គលេខាធិការដ្ឋានត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌនៃលក្ខន្តិកៈដោយឡែកមួយ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង១៦ នៃជំពូកទី៣នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៤ ស្ដីពីថវិការបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមាន២មាត្រា គឺមាត្រា៥៨ និងមាត្រា៥៩។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានថវិកាស្វយ័តសម្រាប់ដំណើរការ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ចែង និងប្រើប្រាស់ថវិកាដោយអនុលោមតាមច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង២ នៃជំពូកទី៤នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៥ ស្ដីពីទោសប្បញ្ញត្តិមាន១មាត្រា គឺមាត្រា៦០។ សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មន្ត្រី បុគ្គលិកក្រោមឱវាទគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងបទវិន័យ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។ បទវិន័យនេះនឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ បទប្បញ្ញត្តិក្នុងមាត្រា៦០ នៃជំពូកទី៥នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៦ ស្ដីពីអន្ដរប្បញ្ញត្តិមាន៤មាត្រា គឺពីមាត្រា៦១ ដល់មាត្រា៦៤ ចែងពីការបន្ដការងាររបស់ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រមទាំងអគ្គលេខាធិការ អគ្គលេខាធិការរង មន្ត្រី បុគ្គលិកនៃអគ្គលេខាធិការដ្ឋានបច្ចុប្បន្នរហូតដល់ពេលដែលមានការតែងតាំងចូលកាន់មុខតំណែងរបស់ប្រធាន អនុប្រធាន សមាជិក អគ្គលេខាធិការ អគ្គលេខាធិការរង មន្ត្រី បុគ្គលិកថ្មី និងការធ្វើសមាហរណកម្ម។ បទប្បញ្ញត្តិក្នុងមាត្រាទាំង៤ នៃជំពូកទី៦នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៧ ស្ដីពីអវសានប្បញ្ញត្តិមាន២មាត្រា គឺមាត្រា៦៥និងមាត្រា៦៦ ចែងពីបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ និងត្រូវជំនួសដោយច្បាប់នេះ ច្បាប់នេះត្រូវប្រកាសជាការប្រញាប់។ បទប្បញ្ញត្តិក្នុងមាត្រាទាំង២ នៃជំពូកទី៧នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ខ្លឹមសារទាំង ៧ជំពូក ៦៦មាត្រានៃច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ។

## **សម្រេច**

**មាត្រា ១.** ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៦ នីតិកាលទី៣ នាថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

**មាត្រា ២.** សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ២៥៥/០០២/២០១៥
ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥

**សេចក្តីសម្រេច**
លេខ : ១៥៤/០០២/២០១៥ កបធ.ច
ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥

**ក្រុមប្រឹក្សាធម្មនុញ្ញ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ២៦២ រ.ស ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៦ នីតិកាលទី៣ នាថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ វេលាម៉ោង ១១ និង ៣០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះ មកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និងការអនុម័តច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅ មាន ៤មាត្រា គឺពីមាត្រា១ ដល់មាត្រា៤ ចែងពីគោលដៅកំណត់បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវអនុវត្តតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវធ្វើឡើងរៀងរាល់ ៥ឆ្នាំម្តង កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ការបោះឆ្នោតត្រូវធ្វើនៅថ្ងៃអាទិត្យតែមួយថ្ងៃ ការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ បទប្បញ្ញត្តិក្នុងមាត្រាទាំង៤នៃជំពូកទី១នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី២ ស្តីពីប្រព័ន្ធបោះឆ្នោត និងការកំណត់អាសនៈ មាន ២មាត្រា គឺមាត្រា៥ និងមាត្រា៦ ចែងពីការជ្រើសតាំងតំណាងរាស្ត្រត្រូវធ្វើឡើងដោយការបោះឆ្នោតជាទូទៅ ជាសកលដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ការបោះឆ្នោតត្រូវធ្វើតាមប្រព័ន្ធសមាមាត្រ អាសនៈនៅក្នុងរដ្ឋសភាមានចំនួន១២៥ បែងចែកទៅតាម២៥មណ្ឌលរាជធានី ខេត្ត។ បទប្បញ្ញត្តិក្នុងមាត្រាទាំង២នៃជំពូកទី២នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៣ ស្តីពីភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត មាន១៦មាត្រា គឺពីមាត្រា៧ ដល់មាត្រា២២ ចែងពីគណបក្សនយោបាយនីមួយៗដែលឈរឈ្មោះបោះឆ្នោតមានសិទ្ធិចាត់តាំងតំណាងរបស់ខ្លួនដើម្បីចូលរួមសង្កេតមើលការបោះឆ្នោតនិងរាប់សន្លឹកឆ្នោតតាមការិយាល័យបោះឆ្នោត បែបបទនៃការដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារពេញសិទ្ធិនិងភ្នាក់ងារបម្រុង គណៈកម្មការឃុំ

សង្កាត់រៀបចំការបោះឆ្នោតត្រូវផ្តល់ប័ណ្ណសម្គាល់ដល់ភ្នាក់ងារគណបក្សនយោបាយ សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលអាចបញ្ជូនតំណាងរបស់ខ្លួនឱ្យមកចូលរួមជាអ្នកសង្កេតការណ៍ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្តល់ប័ណ្ណសម្គាល់ដល់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល សិទ្ធិជំទាស់ឬតវ៉ារបស់ភ្នាក់ងារគណបក្សនយោបាយ របៀបបែបបទនៃការជំទាស់ឬការតវ៉ា បម្រាមចំពោះភ្នាក់ងារគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ក្នុងការសង្កេតមើលដំណើរការនៃការបោះឆ្នោតនិងរាប់សន្លឹកឆ្នោត ការអញ្ជើញតំណាងអង្គការក្រៅរដ្ឋាភិបាលបរទេស តំណាងប្រទេសនានានិងតំណាងអង្គការអន្តរជាតិឱ្យចូលរួមសង្កេតការណ៍ការបោះឆ្នោត និងការតាក់តែងបទបញ្ជាសម្រាប់ភ្នាក់ងារគណបក្សនយោបាយនិងអ្នកសង្កេតការណ៍។ បទប្បញ្ញត្តិក្នុងមាត្រាទាំង១៦នៃជំពូកទី៣នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៤ ស្តីពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនិងបញ្ជីបេក្ខជនឈរឈ្មោះ មាន១៥មាត្រា គឺពីមាត្រា២៣ ដល់មាត្រា៣៧ ចែងពីលក្ខខណ្ឌសម្រាប់ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិនិងមានបំណងឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ ការបើកបញ្ជីចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រូវចាប់ផ្តើម៩០ថ្ងៃមុនថ្ងៃបោះឆ្នោត។ ដើម្បីចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គណបក្សនយោបាយត្រូវបំពេញទម្រង់បែបបទចំនួន១០ចំណុច ហើយត្រូវប្រគល់ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយ៉ាងយូរ៧០ថ្ងៃមុនថ្ងៃបោះឆ្នោត។ ទន្ទឹមនឹងនេះមានចែងអំពីបណ្តឹងតវ៉ារហូតដល់ក្រុមប្រឹក្សាធម្មនុញ្ញ។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យនិងសម្រេចលើបណ្តឹងតវ៉ានេះក្នុងរយៈពេល១០ថ្ងៃយ៉ាងយូរបន្ទាប់ពីបានទទួលពាក្យបណ្តឹង។ ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យនិងសម្រេចលើបណ្តឹងតវ៉ានេះជាបន្ទាន់។ បទប្បញ្ញត្តិក្នុងមាត្រាទាំង១៥នៃជំពូកទី៤នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៥ ស្តីពីការិយាល័យបោះឆ្នោត មាន៦មាត្រា គឺពីមាត្រា៣៨ ដល់មាត្រា៤៣ ចែងពីការបង្កើតការិយាល័យបោះឆ្នោតតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត ការិយាល័យបោះឆ្នោតនីមួយៗត្រូវមានប្រជាពលរដ្ឋមានឈ្មោះបោះឆ្នោតយ៉ាងច្រើន៧៥០នាក់ គ្រប់ការិយាល័យបោះឆ្នោតនិងគ្រប់ការិយាល័យរាប់សន្លឹកឆ្នោតត្រូវមានបរិវេណខាងក្នុងនិងក្រៅដៅសម្គាល់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ឈ្មោះនិងទីតាំងការិយាល័យបោះឆ្នោតដែលបានកំណត់ហើយត្រូវបិទផ្សាយជាសាធារណៈ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង៦នៃជំពូកទី៥នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៦ ស្តីពីការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោត មាន ២៣មាត្រា គឺពីមាត្រា ៤៤ ដល់មាត្រា៦៦ ចែងពីការចុះឈ្មោះបោះឆ្នោតនិងបញ្ជីបោះឆ្នោតត្រូវធានាសិទ្ធិបោះឆ្នោតរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលបានបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធានាឱ្យមានបញ្ជីបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ។ ក្នុងបញ្ជីបោះឆ្នោតត្រូវកត់ត្រាអំពី : នាមត្រកូល នាមខ្លួន ភេទ ថ្ងៃខែឆ្នាំកំណើត លំនៅឋាន ឬ ទីសំណាក់ក្នុងឃុំសង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត និងការដៅសម្គាល់អត្តសញ្ញាណដែលមានតែមួយគត់សម្រាប់អ្នកបោះឆ្នោតម្នាក់ៗ ដូចជារូបថត និងស្នាមម្រាមដៃ ឬ/និងការដៅសម្គាល់ផ្សេងទៀតតាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ទិន្នន័យទាំងអស់ខាងលើនេះត្រូវស្រង់ចេញពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់អ្នកបោះឆ្នោតនោះ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្តល់សុពលភាពនិងប្រកាសផ្សាយបញ្ជីឈ្មោះបោះឆ្នោតផ្លូវការ៩០ថ្ងៃយ៉ាងតិចមុនថ្ងៃបោះឆ្នោត រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនិងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតត្រូវធ្វើចាប់ពីថ្ងៃទី០១ខែឧសភា រហូតដល់ថ្ងៃទី៣១ ខែកក្កដា ជារៀងរាល់ឆ្នាំ។ ក្នុងនេះក៏មានចែងពីបណ្តឹងតវ៉ារហូតដល់ក្រុមប្រឹក្សាធម្មនុញ្ញ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង២៣នៃជំពូកទី៦នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៧ ស្តីពីការឃោសនាបោះឆ្នោត មាន២៥មាត្រា គឺពីមាត្រា៦៧ ដល់មាត្រា៩១ ចែងពីការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះតាមរយៈការឃោសនាបោះឆ្នោត សកម្មភាពនៃការឃោសនាបោះឆ្នោត ការលើកស្លាកសញ្ញាគណបក្សនយោបាយរយៈពេលយុទ្ធនាការនៃការឃោសនាបោះឆ្នោត ការគោរពតាមវិធាន បទប្បញ្ញត្តិនិងគោលការណ៍ដែលមានចែងក្នុងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងក្រមសីលធម៌ បទបញ្ជានិងនីតិវិធីរបស់គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងពេលឃោសនាបោះឆ្នោត។ យុទ្ធនាការឃោសនាបោះឆ្នោតមានរយៈពេល២១ថ្ងៃ ហើយគ្រប់សកម្មភាពនៃការឃោសនាបោះឆ្នោតត្រូវចប់២៤ម៉ោងមុនថ្ងៃបោះឆ្នោត។ ការហែក្បួនរបស់គណបក្សនយោបាយអាចធ្វើបានយ៉ាងច្រើន៤ដងក្នុងអំឡុងពេលឃោសនាបោះឆ្នោត។ រាល់ការស្ទង់មតិនិងការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិពាក់ព័ន្ធកិច្ចការបោះឆ្នោតត្រូវបញ្ឈប់៧ថ្ងៃមុនថ្ងៃបោះឆ្នោត។ អង្គការមិនមែនរដ្ឋាភិបាលឬសមាគមក្នុងស្រុកនិងសមាគមឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេសត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ហាមជនបរទេសដែលមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជាធ្វើសកម្មភាពដោយផ្ទាល់ឬប្រយោលក្នុងការឃោសនាបោះឆ្នោតដើម្បីគាំទ្រឬប្រឆាំងគណបក្សនយោបាយណាមួយឬបេក្ខជនណាម្នាក់។ បទប្បញ្ញត្តិក្នុងមាត្រាទាំង២៥នៃជំពូកទី៧នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៨ ស្តីពីការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត មាន៤៦មាត្រា គឺពីមាត្រា៩២ ដល់មាត្រា១៣៧ ចែងពីការបោះឆ្នោតត្រូវធ្វើតែ១ថ្ងៃចាប់ពី

ម៉ោង៧ព្រឹករហូតដល់ម៉ោង១៥ លើកលែងតែមានសេចក្តីសម្រេចផ្សេងពីនេះរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ សន្លឹកឆ្នោតត្រូវរាប់នៅការិយាល័យបោះឆ្នោតនីមួយៗក្នុងឃុំសង្កាត់។ មន្ត្រីបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗជាអ្នកទទួលខុសត្រូវក្នុងការរាប់សន្លឹកឆ្នោតក្នុងការិយាល័យរបស់ខ្លួន ក្នុងករណីនេះការិយាល័យបោះឆ្នោតនឹងក្លាយទៅជាការិយាល័យរាប់សន្លឹកឆ្នោត។ ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិអាចពិនិត្យតាមដានពេលបោះនិងពេលរាប់សន្លឹកឆ្នោត។ បន្ទាប់ពីបានរាប់សន្លឹកឆ្នោតរួចហើយគណៈកម្មការការិយាល័យបោះឆ្នោតត្រូវធ្វើកំណត់ហេតុអំពីការរាប់សន្លឹកឆ្នោតរួចផ្ញើជូនគណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោតដោយភ្ជាប់ជាមួយនូវបញ្ជីបោះឆ្នោត សន្លឹកឆ្នោតបានការ ពុំបានការ សន្លឹកឆ្នោតដែលពុំបានប្រើប្រាស់ ពាក្យបណ្តឹងជំទាស់ឬតវ៉ាប្រសិនបើមាន និងឯកសារផ្សេងៗបិទនៅការិយាល័យបោះឆ្នោតនិងចែកជូនភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន។ ក្នុងជំពូកនេះក៏មានចែងពីការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនិងបណ្តឹងតវ៉ាអំពីលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ការបែងចែកអាសនៈតាមរាជធានីខេត្ត និងការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោត។ បទប្បញ្ញត្តិក្នុងមាត្រាទាំង៤៦នៃជំពូកទី៨នេះពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៩ ស្តីពីការបាត់បង់អាសនៈនៃរដ្ឋសភា និងការជ្រើសតាំងជំនួស មាន២មាត្រា គឺមាត្រា១៣៨ និងមាត្រា១៣៩ ចែងពីការបោះបង់ចោលអាសនៈរបស់គណបក្សនយោបាយបន្ទាប់ពីការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ការបាត់បង់សមាជិកភាពជាសមាជិករដ្ឋសភា។ បទប្បញ្ញត្តិក្នុងមាត្រាទាំង២នៃជំពូកទី៩នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី១០ ស្តីពីទោសប្បញ្ញត្តិ មាន២៧មាត្រា គឺពីមាត្រា១៤០ ដល់មាត្រា១៦៦ ចែងពីការផាកពិន័យជាប្រាក់ ការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ ការប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញរបស់បុគ្គលដែលទទួលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ បទប្បញ្ញត្តិក្នុងមាត្រាទាំង២៧នៃជំពូកទី១០នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី១១ ស្តីពីអន្តរប្បញ្ញត្តិ មាន៣មាត្រា គឺពីមាត្រា១៦៧ ដល់មាត្រា១៦៩ ចែងពីការរៀបចំបញ្ជីបោះឆ្នោតថ្មីសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៤ និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៧ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦។ បទប្បញ្ញត្តិក្នុងមាត្រាទាំង៣នៃជំពូកទី១១នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី១២ ស្តីពីអវសានប្បញ្ញត្តិ មាន២មាត្រា គឺមាត្រា១៧០ និងមាត្រា១៧១ ចែងពីបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ និងត្រូវជំនួសដោយច្បាប់នេះ។

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង២នៃជំពូកទី១២នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ខ្លឹមសារទាំង ១២ជំពូក ១៧១មាត្រានៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

**សម្រេច**

**មាត្រា ១.** ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៦ នីតិកាលទី៣ នាថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៩៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១.-**

តែងតាំងលោក **សូ សីហា** ជាប្រធាននាយកដ្ឋានឥស្សរិយយស នៃទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៨៦ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យ លេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១** : ប្រគល់ភារកិច្ចជូនលោកស្រី **ឃួន ភូមីសុខា** ឲ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា នៃក្រសួងព័ត៌មាន ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជន ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ២៨៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិ នៃក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦អនក្រ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១**: ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ចំនួន០៤រូប ដូចមានរាយនាមខាងក្រោមៈ

| | |
|---|---|
| ១. លោកឧត្តមសេនីយ៍ទោ **ឡៅ តារាម្យ** | អត្តលេខ ៥៤៧០៨ ពីនាយកវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រនគរបាល ទៅជាទីប្រឹក្សាក្រសួងមហាផ្ទៃ **មានឋានៈស្មើ អគ្គនាយករង** |
| ២. លោកឧត្តមសេនីយ៍ទោ **កើត សំផន** | អត្តលេខ ០៩៩១ ពីនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអនុរក្សពន្ធនាគារ ទៅជាទីប្រឹក្សាក្រសួងមហាផ្ទៃ **មានឋានៈស្មើអគ្គនាយករង** |
| ៣. លោកវរសេនីយ៍ឯក **ឡេង គីមហុង** | អត្តលេខ ៥៧៣១៧ ពីនាយករងវិទ្យាស្ថានគ្រប់គ្រង និងបញ្ញាដឹកនាំ ទៅជានាយកវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រនគរបាល នៃបណ្ឌិត្យសភានគរបាលកម្ពុជា |

៤- លោកវរសេនីយ៍ឯក **ឈឹម ថាណាវណ្ណា** អត្តលេខ ០៤៩០១ ពីនាយករងវិទ្យាស្ថានក្រោយឧត្តមសិក្សា ទៅជានាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអនុរក្សពន្ធនាគារ នៃបណ្ឌិត្យសភានគរបាលកម្ពុជា ។

**មាត្រា២**: បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា៣**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែល មានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៨ ,ខែ មីនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ៣*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៣៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

មាត្រា ១.–

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ៣២ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ សាលាឆាន់ សាលាបាលី កុដិ និងក្លោងទ្វារ នៅ**វត្តសិលាចារិក** (ហៅវត្តក្តីត្រិប) ស្ថិតនៅក្នុងឃុំល្វា ស្រុកព្រះស្តេច នៅ**វត្តឧត្តមខេមរារាម** (ហៅវត្តឧត្តមសមាគម) និងនៅ**វត្តប្រជុំនទី** (ហៅវត្តព្រែកខ្សាយ) ស្ថិតនៅក្នុងស្រុកពាមរក៍ ខេត្តព្រៃវែង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក‑ មេដាយមាសស្ថាបនាជាតិចំនួន ១៣ គ្រឿង ប្រគេន និងផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណវិរិយធម្មោ**គន់ ហេន** | | ព្រះចៅអធិការវត្តប្រជុំនទី | បច្ច័យចំនួន ៧៩.៥៦៣ដុល្លារ |
| ២-លោក **អ៊ុង** | **ស៊ុយគីមលី** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ២៦.៨០០ ដុល្លារ |
| ៣-ឧបាសិកា **ជឹង** | **ជូហុង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៦.៥៤០ ដុល្លារ |
| ៤-លោក **ខូវ** | **ណារ៉ាសែ** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ១៦.១០០ ដុល្លារ |
| ៥-លោក **សេង** | **សុវណ្ណា** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ១៥.៧០០ ដុល្លារ |
| ៦-លោក **នុត** | **ថុនា** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ១៥.៣០០ ដុល្លារ |
| ៧-ឧបាសិកា **ឯក** | **អឿន** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ១៣.០០០ ដុល្លារ |
| ៨-ឧបាសិកា **ជាម** | **ស្រ៊ាន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១២.៥០០ ដុល្លារ |
| ៩-លោកស្រី **ខូវ** | **និត** | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១២.០០០ ដុល្លារ |
| ១០-លោកស្រី **ជុំ** | **សុគន្ធ** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ១០.១២០ ដុល្លារ |
| ១១-លោក **ពៅ** | **ចំរើន** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ១០.០០០ ដុល្លារ |

| | | |
|---|---|---|
| ១២-ឧបាសិកា **គី ម៉ួយ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ១៣-លោកវេជ្ជបណ្ឌិត **លី ឆៀងហ៊ឿង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.០០០ ដុល្លារ |

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ១០ គ្រឿង ប្រគេន និងផ្តល់ជូន :**

| | | |
|---|---|---|
| ១-ព្រះតេជគុណវជីរប្បញ្ញោ **ឈុន សុមនី** | គង់នៅវត្តជ័យមង្គលខេត្តកណ្តាល | បច្ច័យចំនួន ៥.០០០ ដុល្លារ |
| ២-ឧបាសិកា **ឯម យ៉េន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៥.០០០ ដុល្លារ |
| ៣-ឧបាសិកា **លឹម ឆេង** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ៥.០០០ ដុល្លារ |
| ៤-ឧបាសិកា **ព្រីង ណារិទ្ធិ** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ៥.០០០ ដុល្លារ |
| ៥-ឧបាសក **ជុំ ម៉ី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៥.០០០ ដុល្លារ |
| ៦-លោក **អ៊ុច ចន្ធី** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៥.០០០ ដុល្លារ |
| ៧-លោក **លួត ឡាយ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៥.០០០ ដុល្លារ |
| ៨-ឧបាសិកា **លី គីមម៉ុន** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ៥.០០០ ដុល្លារ |
| ៩-លោក **ហាក់ សុផាត** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៥.០០០ ដុល្លារ |
| ១០-ឧបាសិកា **ឈូក ឆៀង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៥.០០០ ដុល្លារ |

**គ. មេដាយសិរីវឌ្ឍិស្ថាបនាជាតិចំនួន ០៩ គ្រឿង ផ្តល់ជូន :**

| | | |
|---|---|---|
| ១-លោកគ្រូពេទ្យ **អ៊ឹម ប៉ាក់** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ១.០០០ ដុល្លារ |
| ២-ឧបាសក **រស់ លីវ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១.០០០ ដុល្លារ |
| ៣-ឧបាសក **ជុំ ឌុន** | អាចារ្យវត្តក្តីត្រិប | ថវិកាចំនួន ១.០០០ ដុល្លារ |
| ៤-ឧបាសក **ស៊ិន សឿន** | អាចារ្យវត្តក្តីត្រិប | ថវិកាចំនួន ១.០០០ ដុល្លារ |
| ៥-ឧបាសក **ម៉ី សុន** | គណៈកម្មការសាងសង់វត្តក្តីត្រិប | ថវិកាចំនួន ១.០០០ ដុល្លារ |
| ៦-ឧបាសក **ប៊ុន សាន** | គណៈកម្មការវត្តក្តីត្រិប | ថវិកាចំនួន ១.០០០ ដុល្លារ |
| ៧-ឧបាសក **ចៀស ចន** | គណៈកម្មការវត្តក្តីត្រិប | ថវិកាចំនួន ១.០០០ ដុល្លារ |
| ៨-ឧបាសក **ម៉ា ផាត់** | គណៈកម្មការវត្តក្តីត្រិប | ថវិកាចំនួន ១.០០០ ដុល្លារ |
| ៩-ឧបាសក **ឈឹម ទោន** | គណៈកម្មការវត្តក្តីត្រិប | ថវិកាចំនួន ១.០០០ ដុល្លារ |

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** អនុក្រ.អនក្រ.ក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .–**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ០៣ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានានៅក្នុងវិស័យព្រះពុទ្ធសាសនា នៅ**វត្តសិលាចារិក** (ហៅវត្តក្តីត្រិប) ស្ថិតនៅក្នុងឃុំល្វា ស្រុកព្រះស្តេច នៅ**វត្តឧត្តមខេមរារាម** (ហៅវត្តឧត្តមសមាគម) និងនៅ**វត្តប្រជុំនទី** (ហៅវត្តព្រែកខ្សាយ) ស្ថិតនៅក្នុងស្រុកពាមរក៍ ខេត្តព្រៃវែង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

១-ព្រះតេជគុណអគ្គគារវតោ **ឡុង សុភាព** គង់នៅវត្តសំពៅមាសរាជធានីភ្នំពេញ បច្ច័យចំនួន ២២.០០០ ដុល្លារ
២-ឯកឧត្តម **សុខ សាធ** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ២១.៥០០ ដុល្លារ
៣-ឯកឧត្តម **សោម អូន** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ២១.៥០០ ដុល្លារ

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣០០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងផ្តល់ជូនសប្បុរសជននៅក្នុង និងក្រៅប្រទេសចំនួន ១៨រូប ដែលបានបរិច្ចាគបច្ច័យជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅ**វត្តអង្គ** និងនៅ**វត្តសិរីសួស្តី** ស្ថិតនៅក្នុងឃុំខុនរ៉ង ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **សៀង សំបុណ្យ** | ព្រះចៅអធិការវត្តអង្គ | បច្ច័យចំនួន ២៨៦.១៥៤ ដុល្លារ |
| ២-ព្រះតេជគុណ | **សាន តុំ** | ព្រះចៅអធិការវត្តសិរីសួស្តី | បច្ច័យចំនួន ៣៣.៥៦៨ ដុល្លារ |
| ៣-ឧបាសិកា | **សាំង ឡុង** | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ៣០.១៩៩ ដុល្លារ |
| ៤-លោក | **ទ្រាំ ចន្ថា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ២៩.៣៣៥ ដុល្លារ |
| ៥-លោក | **ជួប សុន្ធា** | អាចារ្យវត្តសិរីសួស្តី | ថវិកាចំនួន ២៧.៤៥៧ ដុល្លារ |
| ៦-ឧបាសក | **សាន មឿន** | អាចារ្យរងវត្តសិរីសួស្តី | ថវិកាចំនួន ២៦.៨៥៨ ដុល្លារ |
| ៧-ឧបាសក | **តុល សឿន** | គណៈកម្មការវត្តសិរីសួស្តី | ថវិកាចំនួន ២៥.៨១២ ដុល្លារ |
| ៨-លោក | **អឿម ម៉ន** | សប្បុរសជននៅខេត្តកំពង់ឆ្នាំង | ថវិកាចំនួន ២១.៥២២ ដុល្លារ |

| | | | |
|---|---|---|---|
| ៩-លោក | **ឆាយ សារឿន** | សប្បុរសជននៅខេត្តកំពង់ឆ្នាំង | ថវិកាចំនួន ២១.១៣០ ដុល្លារ |
| ១០-ឧបាសក | **ណុប យឿន** | សប្បុរសជននៅខេត្តកំពង់ឆ្នាំង | ថវិកាចំនួន ១៥.២៥៨ ដុល្លារ |
| ១១-លោកស្រី | **យ៉ាង ឡើយលីន** | សប្បុរសជននៅតៃវ៉ាន់ | ថវិកាចំនួន ១៤.៨០០ ដុល្លារ |
| ១២-លោក | **វ៉ែម ឫទ្ធិ** | សប្បុរសជនខ្មែររស់នៅប្រទេសអូស្ត្រាលី | ថវិកាចំនួន ១៣.៧០០ ដុល្លារ |
| ១៣-លោកស្រី | **ផន ភាយ** | សប្បុរសជនខ្មែររស់នៅប្រទេសញ៉ូសេឡេន | ថវិកាចំនួន ១២.៥០០ ដុល្លារ |
| ១៤-លោក | **អ៊ុក នន់** | អាចារ្យវត្តអង្គ | ថវិកាចំនួន ១២.១០០ ដុល្លារ |
| ១៥-ឧបាសិកា | **យាក ហេង** | សប្បុរសជននៅខេត្តកំពង់ឆ្នាំង | ថវិកាចំនួន ១១.២៥៨ ដុល្លារ |
| ១៦-លោក | **គីម ឡេង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១១.១៥៥ ដុល្លារ |
| ១៧-លោក | **ម៉ុក រឿន** | ប្រធានគណៈកម្មការវត្តអង្គ | ថវិកាចំនួន ១១.០៥៥ ដុល្លារ |
| ១៨-លោក | **ហែម ចន្ទី** | សប្បុរសជននៅខេត្តកំពង់ឆ្នាំង | ថវិកាចំនួន ១១.០៥០ ដុល្លារ |

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៣០១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ០៥ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានានៅក្នុងវិស័យព្រះពុទ្ធសាសនា និងអប់រំ នៅ **វត្តសុពណ៌** ស្ថិតនៅក្នុងឃុំកន្ទ្បោមអក ស្រុកព្រះស្តេច និងនៅ**វត្តពញាកេត្តនារាម** ស្ថិតនៅក្នុងឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក. មេដាយមុនីសារាភ័ណ្ឌថ្នាក់ធិបឌិន្ទចំនួន ០៣ គ្រឿង ប្រគេន និងផ្តល់ជូន :**

១-ព្រះតេជគុណ **ខាន់ សុវណ្ណា** ព្រះចៅអធិការវត្តថ្នាខាន់ បច្ច័យចំនួន ៥៨.៧៣០ ដុល្លារ

២-ព្រះតេជគុណ **ជួប យ៉ាន** ព្រះចៅអធិការវត្តសុពណ៌ បច្ច័យចំនួន ៣៥.០០០ ដុល្លារ

៣-លោកឧត្តមសេនីយ៍ត្រី **ម៉ែន សារុន** មេបញ្ជាការសឹករងស្វាយរៀង ថវិកាចំនួន ៣៥.៣៩០ ដុល្លារ

**ខ. មេដាយមុនីសារាភ័ណ្ឌថ្នាក់សេនាចំនួន ០២ គ្រឿង ផ្តល់ជូន :**

១-លោកអនុសេនីយ៍ **លឹម សំអាត** នាយរងការិយាល័យនគរបាលចរាចរណ៍ផ្លូវទឹក ថវិកាចំនួន ២០.៣៩០ ដុល្លារ

២-លោកអនុសេនីយ៍ទោ **សូ** **វណ្ណា** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ២០.១៥០ ដុល្លារ

**មាត្រា ២ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣០៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ២៨ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា និងអប់រំ នៅ**វត្តសុពណ៌** ស្ថិតនៅក្នុងឃុំកន្ទ្យោមអក ស្រុកព្រះស្តេច និងនៅ**វត្តពញាកេត្តនារាម** ស្ថិតនៅក្នុងឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

| | | |
|---|---|---|
| ១-ព្រះតេជគុណ **មុំ គីមលី** | ព្រះចៅអធិការវត្តពញាកេត្តនារាម ដឹកនាំការសាងសង់ | |
| ២-ព្រះតេជគុណ **កែវ យុន** | ព្រះចៅអធិការវត្តសិរីសារពេជ្ជ | បច្ច័យចំនួន ១៨.២០០ ដុល្លារ |
| ៣-ព្រះតេជគុណ **គោយ សាមឿន** | ព្រះចៅអធិការវត្តពេជ្ជរតន៍ | បច្ច័យចំនួន ១៦.៨០០ ដុល្លារ |
| ៤-ព្រះតេជគុណ **តូច ជីម** | ព្រះគ្រូសូត្រឆ្វេងវត្តថ្នាខាន់ | បច្ច័យចំនួន ១២.៨៤៦ ដុល្លារ |
| ៥-ព្រះតេជគុណ **ជិន ឡុន** | ព្រះគ្រូសូត្រស្តាំវត្តថ្នាខាន់ | បច្ច័យចំនួន ១២.១៤៦ ដុល្លារ |
| ៦-ឧបាសិកា **ចាន់ ហ៊ីម** | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ២៨.៤០០ ដុល្លារ |
| ៧-ឧបាសិកា **អ៊ុំ សៀវហ៊ន់** | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ២៥.៦៦០ ដុល្លារ |
| ៨-ឯកឧត្តម **រស់ ចណ្ណា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ២៥.៥០៦ ដុល្លារ |
| ៩-ឧបាសិកា **សិរីវុឌ្ឍ អ៊ាន** | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ២៤.៦៧០ ដុល្លារ |

| | | | |
|---|---|---|---|
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

### សម្រេច

**មាត្រា១.**_បំពាក់ **មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ** ជូនសប្បុរសជនបរទេស ចំនួន០៩រូប ដែលបាននិងកំពុងចូលរួមជួយឧបត្ថម្ភគាំទ្រ ដល់សហគមន៍ឥស្លាមនិងការអភិវឌ្ឍនៅកម្ពុជា ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម ៖

១-Mr. Murat UYAR

២-Haji Ir.Hj Mohd Taquddin @ Mohd Raus Bin Ibrahim

៣-Mr. Ahmad Fadzlullah Hasanuddin

៤-Dr. Abdul Ghaffar Bin Surip

៥-Mr. Redzuan Abd Hanif

៦-Mr. Colonel Adnan bin Hj . Ariffin

៧-Mr. Norjufri Nizar Edrus

៨-Mr. Mohamad Fairuz Shafie

៩-Mr. Airul Azhar Mat Nasit

**មាត្រា២.**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៣១៥ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត//០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត//០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១** : តម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ទោ **ណែម ច័ន្ទថេត** អត្តលេខ ០៩៦៨

២- លោកវរសេនីយ៍ទោ **ថូ ភ័ក្រា** អត្តលេខ ៧១៩១២ ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣១៦ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**មាត្រា ១:** តែងតាំងលោក **យួន សុជាតិ** ជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជំនួសលោក **សរ សាមេធា** ដែលត្រូវចូលនិវត្តន៍ ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជន ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧១ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការបច្ចេកទេសសម្រាប់គម្រោងសាងសង់ ពហុកីឡាដ្ឋានជាតិមរតកតេជោ ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណង ពីសាធារណរដ្ឋប្រជាមានិតចិន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧៤.អនក្រ.បក ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍
- សេចក្តីសម្រេចលេខ ១៦៣.សសរ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសំណើប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា។

## សម្រេច

**ប្រការ ១.**

ត្រូវបានបង្កើតគណៈកម្មការបច្ចេកទេសសម្រាប់គម្រោងសាងសង់ "**ពហុកីឡាដ្ឋានជាតិមរតកតេជោ**" ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងពីសាធារណរដ្ឋប្រជាមានិតចិន ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. **ឯកឧត្តម ថោង ខុន** | ប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | ប្រធាន |
| ២. **ឯកឧត្តម ប៉ែន សុផល** | រដ្ឋលេខាធិការក្រសួងដែនដី រូបនីយកម្ម និងសំណង់ | សមាជិក |
| ៣. **ឯកឧត្តម ហែម វណ្ណឌី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤. **ឯកឧត្តម លូ រ៉ាមីន** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៥. **ឯកឧត្តម ឆា ដុប** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៦. **ឯកឧត្តម អ៊ុក សិទ្ធិជាតិ** | អគ្គនាយកកីឡានៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៧. **ឯកឧត្តម អឿង អូនលី** | អភិបាលរងរាជធានីភ្នំពេញ | សមាជិក |

គណៈកម្មការបច្ចេកទេសនេះមានភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ និងសម្របសម្រួលជាមួយភាគីចិនពាក់ព័ន្ធលើការងារសិក្សាសមិទ្ធិលទ្ធភាពការរៀបចំគម្រោង និងការអនុវត្តគម្រោង។
- ពិនិត្យ សម្រេចលើលក្ខណៈបច្ចេកទេស តម្លៃ និងការអនុវត្តនីតិវិធីនានារបស់គម្រោង រួមទាំងការចុះហត្ថលេខាលើកិច្ចសន្យាពាក់ព័ន្ធនានារបស់គម្រោង។
- ត្រូវរាយការណ៍ជាប្រចាំអំពីលទ្ធផលនៃការងារអនុវត្តគម្រោងជូនអង្គភាព ក្រសួង-ស្ថាប័នតាមភាពចាំបាច់។ ក្នុងករណីត្រូវចាត់វិធានការលើសពីសមត្ថកិច្ចរបស់ខ្លួន គណៈកម្មការអាចសហការ ឬស្នើអោយមានកិច្ចសហការពីក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ តាមតម្រូវការ ចាំបាច់ជាក់ស្តែង។
- សហការជាមួយក្រុមជំនាញបច្ចេកទេសសាធារណរដ្ឋប្រជាមានិតចិន រាល់នីតិវិធីនៃដំណើរការការងារសាងសង់។

**ប្រការ២.**

ត្រូវបានបង្កើតលេខាធិការដ្ឋានរបស់គណៈកម្មការបច្ចេកទេសនៃគម្រោងសាងសង់ **"ពហុកីឡាដ្ឋានជាតិមរតកតេជោ"** ដែលមានសមាសភាព និងភារកិច្ចដូចខាងក្រោម៖

| | | |
|---|---|---|
| ១. **ឯកឧត្តម ជា ប៊ូរ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ និងជាប្រធានផ្នែកហេដ្ឋារចនាសម្ព័ន្ធកីឡាមូលនិធិកីឡានៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | ប្រធាន |
| ២. **ឯកឧត្តម វ៉ាត់ ចំរើន** | អគ្គលេខាធិការគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | អនុប្រធាន |
| ៣. **លោក វ៉ា ហេងដាឡុង** | អនុប្រធានផ្នែកហេដ្ឋារចនាសម្ព័ន្ធកីឡាមូលនិធិកីឡានៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | សមាជិក |
| ៤. **លោក ហង្ស សណ្តាប់** | អគ្គនាយករងទេសចរណ៍ | សមាជិក |

លេខាធិការដ្ឋាននេះមានភារកិច្ច ដូចខាងក្រោម៖

- ជាជំនួយដល់គណៈកម្មការបច្ចេកទេសក្នុងការសម្របសម្រួលការងារជាប្រចាំជាមួយភាគីចិនពាក់ព័ន្ធលើការងារសិក្សាសមិទ្ធិលទ្ធភាព ការរៀបចំគម្រោង និងការអនុវត្តគម្រោង។
- សហការជាមួយភាគីចិនក្នុងការពិនិត្យលើលក្ខណៈបច្ចេកទេស តម្លៃ និងការអនុវត្តនីតិវិធីនានារបស់គម្រោង ដើម្បីរាយការណ៍ជូនប្រធានគណៈកម្មការបច្ចេកទេសពិនិត្យសម្រេច។
- សហការជាមួយភាគីចិន ក្នុងការជ្រើសរើស និងត្រួតពិនិត្យប្លង់ រចនាស្ថាបត្យកម្មនៅសាធារណរដ្ឋប្រជាមានិតចិន ។
- សហការជាមួយក្រុមជំនាញបច្ចេកទេសសាធារណរដ្ឋប្រជាមានិតចិន រាល់នីតិវិធីនៃដំណើរការការងារសាងសង់ និងត្រួតពិនិត្យការងារសាងសង់។
- រាយការណ៍ជាប្រចាំអំពីលទ្ធផលនៃការងារអនុវត្តគម្រោងជូនប្រធានគណៈកម្មការបច្ចេកទេសតាមការចាំបាច់។

**ប្រការ៣.**

គណៈកម្មការនេះមានសិទ្ធិជ្រើសរើសបន្ថែមមន្ត្រីគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា អោយបំពេញការងារតាមតម្រូវការចាំបាច់។

**ប្រការ៤.**

គណៈកម្មការបច្ចេកទេសនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ដើម្បីដំណើរការងាររបស់ខ្លួន តាមការចាំបាច់។

សមាជិកគណៈកម្មការបច្ចេកទេស និងប្រធាន អនុប្រធាន សមាជិកលេខាធិការដ្ឋាន ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ។

**ប្រការ៥.**

គណៈកម្មការបច្ចេកទេសនេះ នឹងត្រូវរំសាយក្រោយចប់ភារកិច្ច។

**ប្រការ៦.**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងពាក់ព័ន្ធ ប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងសាម៉ីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៧២ .សសរ

**សេចក្តីសម្រេច**
**ស្តីពី**
**ការបង្កើតរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស សានកូ ប៉ោយប៉ែត**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច ៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- បានឃើញអនុក្រឹត្យលេខ ៤៨១ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេស សានកូ ប៉ោយប៉ែត
- យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

## សម្រេច

**ប្រការ ១.-** ត្រូវបានបង្កើតរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស សានកូ ប៉ោយប៉ែត ដែលមានទីតាំងស្ថិតនៅភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១- តំណាងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា | ប្រធាន |
| ២- តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៣- តំណាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ៤- តំណាងអគ្គនាយកដ្ឋានត្រួតពិនិត្យទំនិញនាំចេញ-នាំចូល និងបង្ក្រាបការក្លែងបន្លំ នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៥- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៦- តំណាងអាជ្ញាធរខេត្តបន្ទាយមានជ័យ | សមាជិក |

សមាជិករដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ២.-** រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសនេះ មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម :

- ត្រួតពិនិត្យតាមមុខជំនាញសមត្ថកិច្ចចំពោះការចេញពី និងចូលមកនូវទំនិញ មធ្យោបាយ និងជនានុជនគ្រប់រូបរបស់តំបន់ ។ អនុវត្តការត្រួតពិនិត្យបែបបទគយ សម្រាប់ការចេញ ចូលទំនិញ និងសម្រួលបែបបទរដ្ឋបាលដល់កិច្ចដំណើរការរបស់តំបន់ ជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ចជំនាញនានា របស់រាជរដ្ឋាភិបាល ។
- ត្រួតពិនិត្យការអនុវត្តការងាររបស់អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់លើរាល់សកម្មភាពនៅក្នុងតំបន់ ដោយផ្អែកតាមគោលការណ៍ដែលបានកំណត់ ។
- ពិនិត្យលើសំណើសុំចុះបញ្ជីវិនិយោគ ពិនិត្យផ្តល់ជូននូវការលើកទឹកចិត្ត ការចេញលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ វិញ្ញាបនប័ត្រប្រភពដើមទំនិញ ដែលបានស្នើឡើងដោយអ្នកវិនិយោគក្នុងតំបន់ ដើម្បីធ្វើការសម្រេចជូនអ្នកវិនិយោគក្នុងតំបន់ នៅនឹងកន្លែង ។
- ធ្វើការត្រួតពិនិត្យការងារ សកម្មភាពតាមមុខជំនាញនៅក្នុងតំបន់ ។
- សហការជាមួយអ្នកអភិវឌ្ឍន៍តំបន់ ដោះស្រាយការងារ ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន ។
- សម្រួលរាល់បែបបទដែលពាក់ព័ន្ធ ឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព ។
- ធ្វើរបាយការណ៍ការងារប្រចាំខែ ប្រចាំត្រីមាស ឆមាស និងឆ្នាំ ពីសកម្មភាពរបស់តំបន់ ជូនក្រសួង-ស្ថាប័នគ្រប់គ្រង គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ។

- ធ្វើកិច្ចការផ្សេងៗទៀត ក្នុងការសម្របសម្រួល ដោះស្រាយរាល់សំណើរបស់អ្នកវិនិយោគក្នុងតំបន់ ពាក់ព័ន្ធទៅនឹងបណ្តាក្រសួង-ស្ថាប័ននានា របស់រាជរដ្ឋាភិបាល ។

**ប្រការ ៣.-** គ្រប់តំណាងក្រសួង-ស្ថាប័ន ដែលបំពេញភារកិច្ចនៅក្នុងរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស សានកូ ប៉ោយប៉ែត ដូចមានចែងក្នុងប្រការ ១ ត្រូវដំណើរការការងារទៅតាមនីតិវិធីនៃច្បាប់ និងបទប្បញ្ញត្តិទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៤.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងក្រុមហ៊ុន សានកូ ខេមបូ អ៊ិនវេសមេន គ្រប់ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ៣ ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៣ សសរ

**សេចក្តីសម្រេច**
**ស្តីពីការរៀបចំចងសម្ព័ន្ធមេត្រីភាព**
**រវាងកងពលតូចអន្តរាគមន៍ លេខ ១៤ ជាមួយ អគ្គិសនីកម្ពុជា**
**និងអាជ្ញាធរអគ្គិសនីកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការ កែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណូមពរ និងតម្រូវការចាំបាច់នៃការងារ

**សម្រេច**

**ប្រការ ១:** រៀបចំការចងសម្ព័ន្ធមេត្រីភាពរវាង កងពលតូចអន្តរាគមន៍ លេខ ១៤ ជាមួយ អគ្គិសនីកម្ពុជា និងអាជ្ញាធរ អគ្គិសនីកម្ពុជា ។

**ប្រការ ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងពលតូចអន្តរាគមន៍ លេខ ១៤ ដូចមានចែង ក្នុងប្រការ ១ និងអង្គភាពមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ៣ ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...២៥៦......សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិ ជូនអគ្គនាយក នៃគណៈកម្មការមូលបត្រកម្ពុជា

### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល

- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញអនុក្រឹត្យលេខ ៣៣៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៣៣៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញប្រកាសលេខ ២៣៧ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំនិងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៩០១ សហវ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញប្រកាសលេខ ១៩០២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនីសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញប្រកាសលេខ ១៩០៤ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាកម្មវិធីថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.-**

ត្រូវបានប្រគល់សិទ្ធិជូនអគ្គនាយក នៃគណៈកម្មការមូលបត្រកម្ពុជា ជាអាណាប័កផ្ទេរសិទ្ធិ សម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុ នៃថវិការបស់គណៈកម្មការមូលបត្រកម្ពុជា ។

**ប្រការ២.-**

ឥណទានថវិការបស់គណៈកម្មការមូលបត្រកម្ពុជា សម្រាប់ចំណាយក្នុងឆ្នាំ២០១៥ មានទឹកប្រាក់សរុបចំនួន ៨៦៧ ៧០០ ០០០ រៀល "ប្រាំបីរយហុកសិបប្រាំពីរលាន ប្រាំពីររយពាន់រៀលគត់"។

ឥណទាននេះត្រូវបែងចែកតាមចង្កោមសកម្មភាព និងសកម្មភាព (ក្រុម ប្រភេទ ជំពូក គណនី និងអនុគណនី) ដូចមានក្នុងសៀវភៅថវិកាកម្មវិធីដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ នៃអគ្គាធិការដ្ឋាន អគ្គនាយក នៃគណៈកម្មការមូលបត្រកម្ពុជា និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.........សហវ.....

ប្រកាស
ស្តីពី
ការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិ
ជូនអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំ
ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញអនុក្រឹត្យលេខ ៣៣៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៣៣៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញប្រកាសលេខ ២៣៧ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំនិងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៩០១ សហវ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញប្រកាសលេខ ១៩០២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនីសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញប្រកាសលេខ ១៩០៤ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាកម្មវិធីថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.-**

ត្រូវបានប្រគល់សិទ្ធិជូនអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាអាណាប័កផ្ទេរសិទ្ធិ សម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុ នៃថវិការបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**ប្រការ២.-**

ឥណទានថវិការបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ចំណាយក្នុងឆ្នាំ២០១៥ មានទឹកប្រាក់សរុបចំនួន ១ ៦២២ ០០០ ០០០ រៀល "មួយពាន់ប្រាំមួយរយម្ភៃពីរលានរៀលគត់" ។

ឥណទាននេះត្រូវបែងចែកតាមចង្កោមសកម្មភាព និងសកម្មភាព (ក្រុម ប្រភេទ ជំពូក គណនី និងអនុគណនី) ដូចមានក្នុងសៀវភៅថវិកាកម្មវិធីដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ នៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ស៊ុង

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥

បណ្ឌិត. **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ២៥៨ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិ ជូនប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល

- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញអនុក្រឹត្យលេខ ៣៣៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៣៣៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញប្រកាសលេខ ២៣៧ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំនិងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៩០១ សហវ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញប្រកាសលេខ ១៩០២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនីសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញប្រកាសលេខ ១៩០៤ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាកម្មវិធីថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានប្រគល់សិទ្ធិជូនប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ ជាអាណាប័កផ្ទេរសិទ្ធិ សម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុនៃថវិការបស់ក្រុមប្រឹក្សាជាតិគណនេយ្យ។

**ប្រការ២.-**

ឥណទានថវិការបស់ក្រុមប្រឹក្សាជាតិគណនេយ្យ សម្រាប់ចំណាយក្នុងឆ្នាំ២០១៥ មានទឹកប្រាក់សរុបចំនួន ៤៥៨ ៤០០ ០០០ រៀល "បួនរយហាសិបប្រាំបីលាន បួនរយពាន់រៀលគត់"។

ឥណទាននេះត្រូវបែងចែកតាមចង្កោមសកម្មភាព និងសកម្មភាព (ក្រុម ប្រភេទ ជំពូក គណនី និងអនុគណនី) ដូចមានក្នុងសៀវភៅថវិកាកម្មវិធីដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០១៥

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ  សាសនា  ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
លេខ ២៦៥ សហវ.ប្រក

**ប្រកាស**

**ស្តីពី**

**ការកែសម្រួលប្រការ៦ នៃប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ស្តីពី ការកំណត់គោលការណ៍ យន្តការ នីតិវិធី និងការត្រួតពិនិត្យសម្រាប់ការផ្តល់ការលើកទឹកចិត្ត ដោយប្រើប្រាស់ប្រាក់រង្វាន់របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកំណត់គោលការណ៍ យន្តការ នីតិវិធី   និងការត្រួតពិនិត្យសម្រាប់ការផ្តល់ការលើកទឹកចិត្តដោយប្រើប្រាស់ប្រាក់រង្វាន់របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា    ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤    ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
St.92 Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA    Phone : 855-23-724 664    Fax: 855-23-427 798

## សម្រេច

**ប្រការមួយ.-**

កថាខណ្ឌទី១ ចំណុច ក និង វាក្យខណ្ឌទី១ ចំណុច ខ នៃប្រការ ៦ នៃប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកំណត់គោលការណ៍ យន្តការ នីតិវិធី និងការត្រួតពិនិត្យសម្រាប់ការផ្តល់ការលើកទឹកចិត្តដោយប្រើប្រាស់ប្រាក់រង្វាន់របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកែសម្រួលនិងបំពេញបន្ថែមដូចតទៅ÷

**ប្រការ៦ថ្មី.-**

ការលើកទឹកចិត្តត្រូវផ្តល់ទៅតាមសន្ទស្សន៍ តម្លៃឯកតានៃសន្ទស្សន៍ ភាគរយ និងលទ្ធភាពដែលត្រូវបានកំណត់ទៅតាមតាមប្រភេទទាំង៤ ដូចខាងក្រោម÷

ក-**ប្រាក់ឧបត្ថម្ភជីវភាព** ត្រូវផ្តល់ប្រចាំខែ និងត្រូវបានកំណត់ជាសន្ទស្សន៍ ដូចខាងក្រោម÷

១-អគ្គលេខាធិការ/អគ្គនាយក អគ្គលេខាធិការរង/អគ្គនាយករង និងអគ្គាធិការ/អគ្គាធិការរង មានសន្ទស្សន៍ស្មើនឹង ២៥

២-ប្រធាននាយកដ្ឋាន និងអនុប្រធាននាយកដ្ឋាន មានសន្ទស្សន៍ស្មើនឹង ៣០

៣-ប្រធានការិយាល័យ និងអនុប្រធានការិយាល័យ ថ្នាក់កណ្តាល និង ប្រធានការិយាល័យនៃមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគាររាជធានី ខេត្ត មានសន្ទស្សន៍ស្មើនឹង ៧៥

៤-អនុប្រធានការិយាល័យមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រតនាគាររាជធានី ខេត្ត មន្ត្រី មន្ត្រីជាប់កិច្ចសន្យា បុគ្គលិកអណ្តែត ទីប្រឹក្សា និងជំនួយការ មានសន្ទស្សន៍ស្មើនឹង ១០០។

ខ- **ប្រាក់ឧបត្ថម្ភមុខងារ** ត្រូវផ្តល់ប្រចាំខែ និងត្រូវបានកំណត់ជាសន្ទស្សន៍ ដូចខាងក្រោម÷

១-រដ្ឋមន្ត្រី មានសន្ទស្សន៍ស្មើនឹង ២១០៥

២-រដ្ឋលេខាធិការ មានសន្ទស្សន៍ស្មើនឹង ១៣១៦

៣-អនុរដ្ឋលេខាធិការ មានសន្ទស្សន៍ស្មើនឹង ១០៥៣

៤-ប្រធានគម្រោង និង នាយកខុទ្ទកាល័យ មានសន្ទស្សន៍ស្មើនឹង ៥២៦

៥-អនុប្រធានគម្រោង នាយខុទ្ទកាល័យ និងប្រធានក្រុមជំនួយការរដ្ឋលេខាធិការ មានសន្ទស្សន៍ស្មើនឹង ៣៩៥

៦-ប្រធានក្រុមការងារ អនុប្រធានក្រុមជំនួយការរដ្ឋលេខាធិការ ប្រធានក្រុមជំនួយការអនុរដ្ឋលេខាធិការ មានសន្ទស្សន៍ស្មើនឹង ៣៤២

៧-មន្ត្រីជំនាញជាន់ខ្ពស់ និង ទីប្រឹក្សា មានសន្ទស្សន៍ស្មើនឹង ២៦៣

៨-មន្ត្រីជំនាញ មន្ត្រីខុទ្ទកាល័យ និងសមាជិកក្រុមជំនួយការ មានសន្ទស្សន៍ស្មើនឹង ២១១។

**ប្រការពីរ.-**

បទប្បញ្ញត្តិផ្សេងទៀតនៃប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកំណត់គោលការណ៍ យន្តការ នីតិវិធី និងការត្រួតពិនិត្យសម្រាប់ការផ្តល់ការលើកទឹកចិត្ត ដោយប្រើប្រាស់ប្រាក់រង្វាន់របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបន្តអានុភាពអនុវត្ត។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការនៃអគ្គាធិការដ្ឋាន ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៥

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ  សាសនា  ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២៣៥ សហវ.ប្រក

# ប្រកាស
## ស្តីពី
## នីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន
## សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩  និងមាត្រា១០  នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា



ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា     ទូរស័ព្ទ : ៨៥៥-២៣-៧២៨ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលដៅកំណត់នីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ២.-**

ប្រកាសនេះមានគោលបំណងបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព នៃការចំណាយតាមរជ្ជទេយ្យបុរេប្រទានប្រកបដោយភាពទាន់ពេល តម្លាភាព និងគណនេយ្យភាព។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី២

## ការបង្កើតរជ្ជទេយ្យបុរេប្រទាននិងការតែងតាំងរជ្ជទេយ្យករបុរេប្រទាន

### ផ្នែកទី១

### ការបង្កើតរជ្ជទេយ្យបុរេប្រទាន

**ប្រការ៤.-**

រជ្ជទេយ្យបុរេប្រទានគឺជាយន្តការបម្រើឱ្យការចំណាយសម្រាប់ដំណើរការរដ្ឋបាលដែលមានលក្ខណៈជាប្រចាំបន្ទាន់

មានចំនួនទឹកប្រាក់តិច និងមិនអាចរង់ចាំការបោះផ្សាយអាណត្តិបើកប្រាក់តាមនីតិវិធីធម្មតាបាន។ មុខសញ្ញាចំណាយតាមរជ្ជទេយ្យបុរេប្រទាន រួមមាន÷

- ចំណាយចាំបាច់ជាប្រចាំសម្រាប់ការងាររដ្ឋបាល រួមមានជាអាទិ៍ ការទិញសម្ភារៈតិចតួច និងការជួសជុលតូចតាច
- ចំណាយសម្រាប់សង្គ្រោះជាបន្ទាន់និងពិសេស
- ចំណាយសម្រាប់ប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស។

**ប្រការ៥.-**

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ (គំរូឧបសម្ព័ន្ធទី១ នៃប្រកាសនេះ) ត្រូវបង្កើតឡើងដោយជ្រើសរើសយកមាតិកាចំណាយតាមគណនីនិងអនុគណនីនៃជំពូក៦០ "ការទិញ", ជំពូក៦១ "សេវាកម្ម", ជំពូក៦២ "អត្ថប្រយោជន៍សង្គម" និងជំពូក៦៥ "ឧបត្ថម្ភធន" ដែលជាចំណាយចាំបាច់សម្រាប់កិច្ចដំណើរការរដ្ឋបាល ដោយគិតក្នុងកម្រិតអតិបរមាមិនត្រូវលើសពី៣០ភាគរយនៃឥណទានតាមជំពូកដែលជ្រើសរើស។

ក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ឥណទានចំណាយដែលជ្រើសរើសពីគណនីនិងអនុគណនីពុំតម្រូវឱ្យកម្រិតចំនួន៣០ភាគរយស្មើៗគ្នា នៃឥណទានសរុបតាមគណនីនិងអនុគណនីនីមួយៗនោះទេ គឺអាចតិចឬច្រើនទៅតាមតម្រូវការចាំបាច់នៃការចំណាយ ប៉ុន្តែឥណទានចំណាយសរុបតាមជំពូកនីមួយៗ មិនត្រូវលើសពី៣០ភាគរយនៃឥណទានតាមជំពូកដែលបានជ្រើសរើសយកមកបង្កើតរជ្ជទេយ្យបុរេប្រទាននោះឡើយ។

ចំពោះតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលឃុំ សង្កាត់ (គំរូឧបសម្ព័ន្ធទី២នៃប្រកាសនេះ) សម្រាប់ចំណាយចាំបាច់លើកិច្ចដំណើរការរដ្ឋបាល ត្រូវបង្កើតឡើងដោយយកឥណទានសរុបនៃចំណាយចរន្ត ដកឥណទានចំណាយលើបន្ទុកបុគ្គលិក (ជំពូក៦៤) និងចំណាយចរន្តដែលត្រូវទូទាត់តាមនីតិវិធីធម្មតា (ចំណាយអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ និងវិភាគទានសមាគមក្រុមប្រឹក្សាឃុំ សង្កាត់...)។

**ប្រការ៦.-**

ទឹកប្រាក់នៃជុំបង្វិល នៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ ដូចខាងក្រោម÷

- ១ ភាគ ៦ នៃឥណទានរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលរាជធានី ខេត្ត
- ១ ភាគ ៤ នៃឥណទានរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់

យន្តការនៃជុំបង្វិលនិងការបំពេញឡើងវិញ ត្រូវធ្វើឡើងតាមគោលការណ៍ ដូចខាងក្រោម÷

- ទឹកប្រាក់រជ្ជទេយ្យបុរេប្រទានដំបូង ត្រូវកំណត់ចំនួនតិចជាង ឬ ស្មើនឹងទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន
- ការទូទាត់រជ្ជទេយ្យបុរេប្រទានក្នុងមួយលើក ត្រូវកំណត់មិនឱ្យលើសពីទំហំទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន
- ការទូទាត់រជ្ជទេយ្យបុរេប្រទានត្រូវបានអនុញ្ញាតឱ្យធ្វើឡើងច្រើនលើកទៅតាមតម្រូវការជាក់ស្តែង ដោយមិនកំណត់ពេលវេលា ហើយមិនត្រូវលើសឥណទានប្រចាំឆ្នាំ ប៉ុន្តែត្រូវធានានិរន្តរភាពនៃចំណាយលើដំណើរការរដ្ឋបាលរហូតដល់ដំណាច់ឆ្នាំថវិកានីមួយៗ

- ទឹកប្រាក់រជ្ជទេយ្យបុរេប្រទាន ត្រូវបានបំពេញឡើងវិញក្រោយការទូទាត់មួយលើកៗ លើកលែងការទូទាត់ក្រោយកាលបរិច្ឆេទនៃការបើកសាច់ប្រាក់ចុងក្រោយដែលកំណត់ដោយប្រកាសស្តីពីការបិទបញ្ជីចំណូលចំណាយថវិកាប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៧.-**

រជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបង្កើតឡើង០១ឆ្នាំម្តងនៅរៀងរាល់ដើមឆ្នាំថវិកានីមួយៗ និងត្រូវបានកំណត់ ដូចខាងក្រោម÷

- រជ្ជទេយ្យបុរេប្រទានរដ្ឋបាលរាជធានី ខេត្ត ត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត តាមរយៈមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត និងរតនាគាររាជធានី ខេត្ត (គំរូឧបសម្ព័ន្ធទី៣នៃប្រកាសនេះ)
- រជ្ជទេយ្យបុរេប្រទានរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ តាមរយៈមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត និងរតនាគាររាជធានី ខេត្ត(គំរូឧបសម្ព័ន្ធទី៣នៃប្រកាសនេះ)
- រជ្ជទេយ្យបុរេប្រទានរដ្ឋបាលឃុំ សង្កាត់ (គំរូឧបសម្ព័ន្ធទី៤នៃប្រកាសនេះ) ត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់មេឃុំ ឬ ចៅសង្កាត់ តាមរយៈរតនាគាររាជធានី ខេត្ត។

## ផ្នែកទី២
## ការតែងតាំងរជ្ជទេយ្យករបុរេប្រទាន

**ប្រការ៨.-**

រជ្ជទេយ្យករបុរេប្រទាន អាចមានរជ្ជទេយ្យករបុរេប្រទានរង មួយចំនួនជាជំនួយការ តាមការចាំបាច់។

ការតែងតាំងរជ្ជទេយ្យករបុរេប្រទាននិងរជ្ជទេយ្យករបុរេប្រទានរងត្រូវបានកំណត់ ដូចខាងក្រោម÷

- សម្រាប់រដ្ឋបាលរាជធានី ខេត្ត (គំរូឧបសម្ព័ន្ធទី៥នៃប្រកាសនេះ) ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត តាមរយៈរតនាគាររាជធានី ខេត្ត
- សម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ (គំរូឧបសម្ព័ន្ធទី៥នៃប្រកាសនេះ) ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ តាមរយៈរតនាគាររាជធានី ខេត្ត
- សម្រាប់រដ្ឋបាលឃុំ សង្កាត់ (គំរូឧបសម្ព័ន្ធទី៦នៃប្រកាសនេះ) ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់មេឃុំ ឬ ចៅសង្កាត់ តាមរយៈរតនាគាររាជធានី ខេត្ត។

**ប្រការ៩.-**

រជ្ជទេយ្យករបុរេប្រទាននិងរជ្ជទេយ្យករបុរេប្រទានរងត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការដែលមានលក្ខណៈសម្បត្តិល្អនិងមានការយល់ដឹងច្បាស់លាស់អំពីកិច្ចបញ្ជិកាគណនេយ្យ ដែលអាចគ្រប់គ្រងលើការចំណាយតាមរជ្ជទេយ្យបុរេប្រទានបានត្រឹមត្រូវប្រកបដោយប្រសិទ្ធភាពខ្ពស់។

### ផ្នែកទី៣
### ការទទួលខុសត្រូវរបស់រជ្ជទេយ្យករបុរេប្រទាន

**ប្រការ១០.-**

អនុលោមតាមមាត្រា២៥ នៃអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ រជ្ជទេយ្យករបុរេប្រទាន និងរជ្ជទេយ្យករបុរេប្រទានរងត្រូវទទួលខុសត្រូវផ្ទាល់ខ្លួន ផ្នែករដ្ឋបាល ផ្នែករដ្ឋប្បវេណី ផ្នែកព្រហ្មទណ្ឌ និងជាប្រាក់កាស ចំពោះការទុកដាក់ថែរក្សានូវមូលនិធិដែលខ្លួនបានទទួល បានចំណាយ និងការទុកដាក់ថែរក្សាលិខិតយុត្តិការ ព្រមទាំង ការកាន់កាប់បញ្ជីគណនេយ្យនៃកិច្ចប្រតិបត្តិការ។

### ជំពូកទី៣
### កិច្ចដំណើរការនៃរជ្ជទេយ្យបុរេប្រទាន
### ផ្នែកទី១
### ការដកប្រាក់រជ្ជទេយ្យបុរេប្រទាន

**ប្រការ១១.-**

បន្ទាប់ពីទទួលការតែងតាំងរួចមក រជ្ជទេយ្យករបុរេប្រទានត្រូវបំពេញបែបបទស្នើសុំបើកគណនីរជ្ជទេយ្យករបុរេប្រទាន នៅរតនាគាររាជធានី ខេត្ត។

**ប្រការ១២.-**

រជ្ជទេយ្យករបុរេប្រទានត្រូវប្រគល់សេចក្តីសម្រេចស្តីពីការតែងតាំងរជ្ជទេយ្យករបុរេប្រទាន និងសេចក្តីសម្រេច ស្តីពីការបង្កើតរជ្ជទេយ្យបុរេប្រទាន ដោយភ្ជាប់មកជាមួយនូវតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានជូនគណនេយ្យករ សាធារណៈ០១ច្បាប់និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ០១ច្បាប់ លើកលែងចំពោះរដ្ឋបាលឃុំ សង្កាត់ ដែលត្រូវផ្ញើជូនតែ គណនេយ្យករសាធារណៈ។ បន្ទាប់មក រជ្ជទេយ្យករបុរេប្រទាននិងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវរក្សាទុកឥណទានជា បណ្តោះអាសន្នលើសលាកប័ត្រតាមដានការប្រើប្រាស់ឥណទានទៅតាមមាតិកាចំណាយថវិកានៃតារាងឧបសម្ព័ន្ធរជ្ជទេយ្យ បុរេប្រទាន ដែលមានចំនួនទឹកប្រាក់ស្មើនឹងឥណទានរជ្ជទេយ្យបុរេប្រទាន។ ដោយឡែកគណនេយ្យករសាធារណៈ ត្រូវរក្សាទុកឥណទានជាបណ្តោះអាសន្ន ដែលមានចំនួនទឹកប្រាក់ស្មើនឹង០១ជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន។

**ប្រការ១៣.-**

ចំពោះការដកសាច់ប្រាក់រជ្ជទេយ្យបុរេប្រទាននៅជុំបង្វិលដំបូង រជ្ជទេយ្យករបុរេប្រទានអាចស្នើសុំដកប្រាក់រជ្ជទេយ្យ បុរេប្រទានស្មើ ឬ តិចជាងចំនួនទឹកប្រាក់នៃជុំបង្វិលតាមរយៈប័ណ្ណដកប្រាក់រជ្ជទេយ្យបុរេប្រទានដែលមានចុះហត្ថលេខា ត្រឹមត្រូវ ដោយពុំចាំបាច់បញ្ជាក់អំពីមុខសញ្ញាចំណាយ និងពុំចាំបាច់ស្នើសុំទិដ្ឋាការរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុឡើយ។

### ផ្នែកទី២
### ការចំណាយនិងការទូទាត់ប្រាក់រជ្ជទេយ្យបុរេប្រទាន

**ប្រការ១៤.-**

ជាគោលការណ៍ ការចំណាយនិងការទូទាត់ប្រាក់រជ្ជទេយ្យបុរេប្រទានត្រូវមានសក្ខីប័ត្របញ្ជាក់ត្រឹមត្រូវ។ មុននឹង ធ្វើការចំណាយប្រាក់រជ្ជទេយ្យបុរេប្រទាន រជ្ជទេយ្យករបុរេប្រទានត្រូវស្នើសុំគោលការណ៍ចំណាយទៅអាណាប័ក ឬ អ្នក

ដែលទទួលបានការផ្ទេរសិទ្ធិពីអាណាប័ក។ ក្រោយពីទទួលបានគោលការណ៍ចំណាយ រដ្ឋទេយ្យករបុរេប្រទានត្រូវអនុវត្តការទូទាត់ចំណាយ ដោយតម្រូវឱ្យអ្នកទទួលប្រាក់រដ្ឋទេយ្យបុរេប្រទានចុះហត្ថលេខាបញ្ជាក់លើសក្ខីប័ត្រអំពីចំនួនទឹកប្រាក់ដែលបានទទួល។

**ប្រការ១៥.-**

រាល់ប័ណ្ណចំណាយត្រូវភ្ជាប់មកជាមួយនូវគោលការណ៍ចំណាយ វិក្កយប័ត្រ ឬសក្ខីប័ត្រចំណាយ ដែលរដ្ឋទេយ្យករបុរេប្រទានបានធ្វើការទូទាត់ដោយមានការបញ្ជាក់ទទួលស្គាល់ពីអាណាប័ក ឬពីអ្នកដែលទទួលបានការផ្ទេរសិទ្ធិពីអាណាប័ក។

**ប្រការ១៦.-**

ចំនួនទឹកប្រាក់សម្រាប់មួយគោលការណ៍ចំណាយ ឬ មួយប័ណ្ណចំណាយ ត្រូវបានកំណត់ជាអតិបរមា ដូចខាងក្រោម÷

- រដ្ឋបាលរាជធានី ខេត្ត ១ ៥០០ ០០០(មួយលានប្រាំរយពាន់)រៀល
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ ១ ០០០ ០០០(មួយលាន) រៀល
- រដ្ឋបាលឃុំ សង្កាត់ ៥០០ ០០០(ប្រាំរយពាន់) រៀល។

គោលការណ៍ចំណាយខាងលើ ត្រូវបានលើកលែងចំពោះចំណាយសង្គ្រោះជាបន្ទាន់និងពិសេស និងចំណាយដែលមានរបបកំណត់ច្បាស់លាស់ ដែលត្រូវទូទាត់តាមការចំណាយជាក់ស្តែង។

រដ្ឋទេយ្យករបុរេប្រទានត្រូវជៀសវាងដាច់ខាតនូវការបំបែកប័ណ្ណចំណាយទៅតាមទីកន្លែង ឬ គោលដៅចំណាយ ពេលវេលា ទឹកប្រាក់ចំណាយ និងសមាសធាតុនៃមុខសញ្ញាចំណាយក្នុងគោលបំណងគេចវេសការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ។

**ប្រការ១៧.-**

ប្រសិនបើអាណាប័កពិនិត្យឃើញថាលិខិតយុត្តិការចំណាយត្រឹមត្រូវហើយ អាណាប័កត្រូវបោះផ្សាយអាណត្តិនិយ័តកម្មដើម្បីទូទាត់ចំណាយរដ្ឋទេយ្យបុរេប្រទានរួចផ្ញើទៅមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដើម្បីផ្តល់ទិដ្ឋាការ (លើកលែងចំពោះរដ្ឋបាលឃុំ សង្កាត់ ពុំចាំបាច់ទទួលការផ្តល់ទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេ) ។ ប៉ុន្តែក្នុងករណីដែលអាណាប័កពិនិត្យឃើញថាលិខិតយុត្តិការចំណាយមួយចំនួនពុំមានលក្ខណៈត្រឹមត្រូវទេ អាណាប័កត្រូវបញ្ជូនលិខិតយុត្តិការចំណាយនោះទៅរដ្ឋទេយ្យករបុរេប្រទានវិញដើម្បីធ្វើការកែតម្រូវ។

**ប្រការ១៨.-**

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ អាចបញ្ជូនអាណត្តិនិយ័តកម្មនិងលិខិតយុត្តិការចំណាយរបស់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រឡប់ទៅអាណាប័កវិញ ដើម្បីកែតម្រូវ ក្នុងករណីពិនិត្យឃើញថា ពុំទាន់មានលក្ខណៈត្រឹមត្រូវនិងគ្រប់គ្រាន់។ ក្នុងករណីពិនិត្យឃើញថាត្រឹមត្រូវហើយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវផ្តល់ទិដ្ឋាការនិងបញ្ជូនអាណត្តិនិយ័តកម្មនិងលិខិតយុត្តិការចំណាយពាក់ព័ន្ធ ទៅគណនេយ្យករសាធារណៈ ដោយភ្ជាប់ជាមួយនូវដីកាអមលិខិតយុត្តិការចំនួន០១ច្បាប់ ដើម្បីគណនេយ្យករសាធារណៈធ្វើការត្រួតពិនិត្យនិងអនុវត្តមុខការបន្ត។ ក្នុងករណីដែលអាណត្តិនិយ័តកម្មនិងលិខិតយុត្តិការចំណាយនោះពុំត្រឹមត្រូវ ឬ ពុំគ្រប់គ្រាន់ទេ គណនេយ្យករសាធារណៈត្រូវបញ្ជូនអាណត្តិនិយ័តកម្មនោះត្រឡប់ទៅអាណាប័កវិញតាមរយៈមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដោយមានការបញ្ជាក់អំពីចំណុចខ្វះខាត។ ក្រោយពីបានកែតម្រូវលើអាណត្តិនិយ័តកម្មឬលិខិតយុត្តិការចំណាយរួច អាណាប័កត្រូវផ្ញើជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុសាជាថ្មី ដែលត្រូវបញ្ជូនបន្តមកគណនេយ្យករសាធារណៈ។

គណនេយ្យករសាធារណៈ អាចបញ្ជូនអាណត្តិនិយ័តកម្មនិងលិខិតយុត្តិការចំណាយរបស់រដ្ឋបាលឃុំ សង្កាត់ ត្រឡប់ទៅអាណាប័កវិញដើម្បីកែតម្រូវ ក្នុងករណីពិនិត្យឃើញថា ពុំទាន់មានលក្ខណៈត្រឹមត្រូវនិងគ្រប់គ្រាន់ដោយមានបញ្ជាក់អំពីចំណុចខ្វះខាត។ ក្រោយពីបានកែតម្រូវលើអាណត្តិនិយ័តកម្ម ឬ លិខិតយុត្តិការចំណាយរួច អាណាប័ក ត្រូវផ្ញើមកគណនេយ្យករសាធារណៈសាជាថ្មី។

ក្នុងករណីពិនិត្យឃើញថាមានលក្ខណៈត្រឹមត្រូវនិងគ្រប់គ្រាន់ហើយ គណនេយ្យករសាធារណៈត្រូវផ្ដល់ការទូទាត់អាណត្តិនិយ័តកម្ម រួចត្រូវកត់ត្រាទៅក្នុងសលាកប័ត្រតាមដានការប្រើប្រាស់ឥណទាននិងចាត់ទុកជាចំណាយថវិកា ព្រមទាំងធ្វើការកត់ត្រាចំនួនទឹកប្រាក់នោះទៅក្នុងគណនីរជ្ជទេយ្យករបុរេប្រទាន។

បន្ទាប់មក រជ្ជទេយ្យករបុរេប្រទានអាចដកប្រាក់សាជាថ្មីពីគណនេយ្យករសាធារណៈតាមរយៈប័ណ្ណដកប្រាក់រជ្ជទេយ្យបុរេប្រទាន។

**ប្រការ១៩.-**

អាណាប័កអាចបោះផ្សាយអាណត្តិនិយ័តកម្មក្នុងទឹកប្រាក់តិចជាង ឬ ស្មើនឹងទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ប៉ុន្តែមិនអនុញ្ញាតឱ្យធ្វើការបោះផ្សាយអាណត្តិនិយ័តកម្មដើម្បីទូទាត់រជ្ជទេយ្យបុរេប្រទាន ដែលមានចំនួនទឹកប្រាក់ស្មើនឹងទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន សម្រាប់តែគណនី ឬ អនុគណនីណាមួយឡើយ។

**ប្រការ២០.-**

ការចំណាយតាមរជ្ជទេយ្យបុរេប្រទានត្រូវប្រព្រឹត្តទៅតាមវដ្ដនៃរជ្ជទេយ្យបុរេប្រទានដែលចែកចេញជា ០៤ដំណាក់កាលដូចខាងក្រោម÷

- រជ្ជទេយ្យករបុរេប្រទានដកប្រាក់រជ្ជទេយ្យបុរេប្រទាន
- ចំណាយប្រាក់រជ្ជទេយ្យបុរេប្រទាន
- រជ្ជទេយ្យករបុរេប្រទានរៀបចំលិខិតយុត្តិការ ដាក់ជូនអាណាប័កបោះផ្សាយអាណត្តិនិយ័តកម្ម ដើម្បីទូទាត់
- ទទួលបានទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ (លើកលែងចំពោះរដ្ឋបាលឃុំ សង្កាត់) និងទទួលបានការឯកភាពទូទាត់ពីគណនេយ្យករសាធារណៈជាចំណាយថវិកាស្ថាពរ។

កិច្ចដំណើរការចំណាយតាមវដ្ដនៃរជ្ជទេយ្យបុរេប្រទាន ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់គណនេយ្យករសាធារណៈ។

គំនូសបំព្រួញអំពីវដ្តនៃរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ដូចខាងក្រោម÷




### ផ្នែកទី៣
### វិធានការអនុវត្តនាពេលដំណាច់ឆ្នាំថវិកា

**ប្រការ២១.-**

នាពេលដំណាច់ឆ្នាំថវិកា ក្នុងករណីមានប្រាក់រជ្ជទេយ្យបុរេប្រទាននៅសល់ រជ្ជទេយ្យករបុរេប្រទានត្រូវយកប្រាក់ដែលនៅសល់នោះ មកបង់ជូនគណនេយ្យករសាធារណៈវិញ ដើម្បីចុះកិច្ចបញ្ជិកាជម្រះបញ្ជីរជ្ជទេយ្យបុរេប្រទាន។

**ប្រការ២២.-**

រជ្ជទេយ្យករបុរេប្រទានត្រូវប្រមូលលិខិតយុត្តិការចំណាយ ជូនអាណាប័កដើម្បីធ្វើការបោះផ្សាយអាណត្តិនិយ័តកម្ម រួចបញ្ជូនមកមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ (លើកលែងចំពោះរដ្ឋបាលឃុំ សង្កាត់) និងគណនេយ្យករសាធារណៈ យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំថវិកា ដើម្បីទូទាត់ជម្រះបញ្ជីរជ្ជទេយ្យបុរេប្រទានឱ្យបានទាន់ក្នុងឆ្នាំថវិកា។

## ជំពូកទី៤
## គណនេយ្យរជ្ជទេយ្យបុរេប្រទាន
### ផ្នែកទី១
### គោលការណ៍ទូទៅ

**ប្រការ២៣.-**

រជ្ជទេយ្យករបុរេប្រទានត្រូវកាន់បញ្ជីគណនេយ្យទ្វេភាគ ក្នុងលក្ខខណ្ឌច្រើន ឬ តិច ធ្វើឱ្យបានសាមញ្ញទៅតាម

ទំហំរជ្ជទេយ្យបុរេប្រទាន។ បញ្ជីគណនេយ្យរបស់រជ្ជទេយ្យករបុរេប្រទានត្រូវមាន បញ្ជីបេឡា ទិន្នានុប្បវត្តិទូទៅនិង សៀវភៅធំ។

រជ្ជទេយ្យករបុរេប្រទានត្រូវរៀបចំរបាយការណ៍គណនេយ្យរជ្ជទេយ្យបុរេប្រទានដែលត្រូវមានតារាងតុល្យភាពគណនី នៃរជ្ជទេយ្យបុរេប្រទាន។

កិច្ចបញ្ជិកាគណនេយ្យនិងរបាយការណ៍រជ្ជទេយ្យបុរេប្រទាន ត្រូវកត់ត្រានិងរៀបចំជាបន្តបន្ទាប់ចាប់ពីដើមឆ្នាំ រហូតដល់ដំណាច់ឆ្នាំថវិកានីមួយៗ។ នៅសប្តាហ៍ទី១ នៃខែមករា នាដើមឆ្នាំថវិកាបន្ទាប់ រជ្ជទេយ្យករបុរេប្រទាន ត្រូវចាប់ផ្តើមអនុវត្តការគ្រប់គ្រងជាថ្មី ដោយដុំបច្ចិលដំបូងនិងត្រូវយោងតាមសេចក្តីសម្រេចស្តីពីការបង្កើតរជ្ជទេយ្យ បុរេប្រទានក្នុងឆ្នាំកំពុងអនុវត្ត។

**ប្រការ២៤.-**

បញ្ជីគណនេយ្យរបស់រជ្ជទេយ្យករបុរេប្រទាន មានដូចខាងក្រោម៖

- បញ្ជីបេឡា៖ សម្រាប់កត់ត្រានូវទឹកប្រាក់រជ្ជទេយ្យបុរេប្រទានដែលបានទទួលពីគណនេយ្យករសាធារណៈ ទឹកប្រាក់ដែលបានចំណាយនិងទឹកប្រាក់ដែលនៅសល់
- ទិន្នានុប្បវត្តិទូទៅ-សៀវភៅធំ៖ សម្រាប់កត់ត្រាប្រតិបត្តិការរជ្ជទេយ្យបុរេប្រទានជា០២ផ្នែក ដូចខាងក្រោម៖
  - ១-ផ្នែកទិន្នានុប្បវត្តិទូទៅ៖ សម្រាប់កត់ត្រាប្រតិបត្តិការរជ្ជទេយ្យបុរេប្រទានប្រចាំថ្ងៃទៅតាមលំដាប់ដែល មានជាអាទិ៍លេខរៀង, កាលបរិច្ឆេទ, ឯកសារយោងដែលមានជាអាទិ៍ប័ណ្ណចំណូលនិងប័ណ្ណចំណាយ, លេខគណនីរជ្ជទេយ្យបុរេប្រទាន, បរិយាយ, ទឹកប្រាក់ខាងឥណពន្ធ និងទឹកប្រាក់ខាងឥណទាន។
  - ២-ផ្នែកសៀវភៅធំ៖ សម្រាប់កត់ត្រាប្រតិបត្តិការរជ្ជទេយ្យបុរេប្រទានប្រចាំថ្ងៃទៅតាមផ្នែកខាងឥណពន្ធ និងផ្នែកខាងឥណទាននៃគណនីរជ្ជទេយ្យបុរេប្រទាននីមួយៗ។ សៀវភៅធំត្រូវបូកសរុបនៅដំណាច់ ខែនីមួយៗ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំតារាងតុល្យភាពគណនីនៃរជ្ជទេយ្យបុរេប្រទានប្រចាំខែ។

ទិន្នានុប្បវត្តិទូទៅ-សៀវភៅធំ ត្រូវបូកសរុបនៅដំណាច់ខែនីមួយៗនិងមានការចុះហត្ថលេខាបញ្ជាក់ដោយ រជ្ជទេយ្យករបុរេប្រទាន នាយកទីចាត់ការហិរញ្ញវត្ថុ/ប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ និងអាណាប័ក។

របាយការណ៍គណនេយ្យរជ្ជទេយ្យបុរេប្រទានត្រូវមានតារាងតុល្យភាពគណនីរជ្ជទេយ្យបុរេប្រទាន ដែលកត់ត្រា ប្រតិបត្តិការរជ្ជទេយ្យបុរេប្រទានសរុបប្រចាំខែ ទៅតាមផ្នែកខាងឥណពន្ធនិងផ្នែកខាងឥណទាននៃគណនីរជ្ជទេយ្យ បុរេប្រទាន។ តារាងតុល្យភាពគណនីរជ្ជទេយ្យបុរេប្រទានរៀបរាប់អំពីចលនានិងសមតុល្យទៅតាមលំដាប់លេខគណនី រជ្ជទេយ្យបុរេប្រទានពីតូចទៅធំ។

នៅដំណាច់ខែនីមួយៗ រជ្ជទេយ្យករបុរេប្រទានត្រូវបញ្ចប់កិច្ចបញ្ជិកា និងរៀបចំតារាងតុល្យភាពគណនីរជ្ជទេយ្យ បុរេប្រទាន ដោយមានចុះហត្ថលេខាបញ្ជាក់ពីរជ្ជទេយ្យករបុរេប្រទាន និងនាយកទីចាត់ការហិរញ្ញវត្ថុ/ប្រធានការិយាល័យ រដ្ឋបាលនិងហិរញ្ញវត្ថុ ហើយត្រូវផ្ញើទៅគណនេយ្យករសាធារណៈចំនួន០១ច្បាប់ ឱ្យបានយ៉ាងយូរត្រឹមថ្ងៃទី១៥ នៃខែ បន្ទាប់។

## ផ្នែកទី២

## កិច្ចបញ្ជិកាគណនេយ្យដែលកាន់កាប់ដោយគណនេយ្យករសាធារណៈ

**ប្រការ២៥.-**

កិច្ចប្រតិបត្តិការរជ្ជទេយ្យបុរេប្រទានត្រូវតាមដានដោយគណនេយ្យករសាធារណៈ។ កិច្ចបញ្ជិកាគណនេយ្យដែលកាន់កាប់ដោយគណនេយ្យករសាធារណៈ មានដូចតទៅ៖

**ក- ការបើកផ្តល់ប្រាក់ដល់រជ្ជទេយ្យករបុរេប្រទាន**

កត់ត្រា៖

ឥណពន្ធគណនីរជ្ជទេយ្យករបុរេប្រទាន (លេខ ១៤០១)

ឥណទានគណនីហិរញ្ញវត្ថុ (លេខ១១០១, ១១០៥, ១១០៦, ១៣០១)។

លិខិតយុត្តិការ៖ ប័ណ្ណដកប្រាក់រជ្ជទេយ្យបុរេប្រទាន។

**ខ- ការទទួលអាណត្តិនិយ័តកម្មនិងលិខិតយុត្តិការចំណាយ**

កត់ត្រា៖

ឥណពន្ធគណនីចំណាយថវិកា (៦...)

ឥណទានគណនីរជ្ជទេយ្យករបុរេប្រទាន (លេខ ១៤០១)។

លិខិតយុត្តិការ៖ អាណត្តិនិយ័តកម្មនិងលិខិតយុត្តិការចំណាយ។

**គ- ការបញ្ចប់កិច្ចប្រតិបត្តិការនៃរជ្ជទេយ្យបុរេប្រទាន**

ពេលទទួលមូលនិធិដែលនៅសល់សងវិញដោយរជ្ជទេយ្យករបុរេប្រទាន ត្រូវកត់ត្រា៖

ឥណពន្ធគណនីហិរញ្ញវត្ថុ (លេខ ១១០១, ១១០៥, ១១០៦,១៣០១)

ឥណទានគណនីរជ្ជទេយ្យករបុរេប្រទាន(លេខ ១៤០១)។

លិខិតយុត្តិការ៖ សំណើសុំបង់ប្រាក់និងប័ណ្ណបង់ប្រាក់ ឬ ប្រកាសឥណទានពីធនាគារ។

## ផ្នែកទី៣

## កិច្ចបញ្ជិកាគណនេយ្យដែលកាន់កាប់ដោយរជ្ជទេយ្យករបុរេប្រទាន

**ប្រការ២៦.-**

គណនីដែលកាន់កាប់ដោយរជ្ជទេយ្យករបុរេប្រទានរួមមាន៖

- គណនីបុរេប្រទានពីរតនាគារ (លេខ ១១១៨) ប្រើប្រាស់សម្រាប់កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានដែលបានទទួលពីគណនេយ្យករសាធារណៈ
- គណនីមូលប្បទានប័ត្រធ្វើបេឡានិច្ច័យ(លេខ១១១៦) ប្រើប្រាស់សម្រាប់កត់ត្រាចំនួនទឹកប្រាក់នៃមូលប្បទានប័ត្រដែលបានទទួលពីគណនេយ្យករសាធារណៈ ហើយរង់ចាំការជម្រះពីធនាគារ
- គណនីបេឡាសាច់ប្រាក់ (លេខ ១៣០១) ប្រើប្រាស់សម្រាប់កត់ត្រាចំនួនសាច់ប្រាក់ចំណូល ចំណាយបេឡាប្រចាំថ្ងៃ

- គណនីចំណាយមុនការធ្វើអាណត្តិកិច្ច (លេខ ១៥០៥) ប្រើប្រាស់សម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយមុនការបោះផ្សាយអាណត្តិនិយ័តកម្ម
- គណនី លិខិតយុត្តិការចំណាយបានបញ្ជូនរបស់រដ្ឋទេយ្យករបុរេប្រទាន (លេខ ១៥០៧) ប្រើប្រាស់សម្រាប់កត់ត្រាចំនួនទឹកប្រាក់សរុបនៃលិខិតយុត្តិការចំណាយភ្ជាប់តាមអាណត្តិនិយ័តកម្មដែលបានបញ្ជូនទៅរតនាគាររង់ចាំការទូទាត់។

កិច្ចបញ្ជិកាគណនេយ្យដែលកាន់កាប់ដោយរដ្ឋទេយ្យករបុរេប្រទាន មានដូចតទៅ÷

**ក. ការទទួលមូលប្បទានប័ត្រដែលផ្តល់ដោយគណនេយ្យករសាធារណៈ**

កត់ត្រា÷

ឥណពន្ធ គណនី មូលប្បទានប័ត្រធ្វើបេឡានិច្ច័យ (លេខ ១១១៦)

ឥណទាន គណនី បុរេប្រទានពីរតនាគារ (លេខ ១១១៨)។

**ខ. ការបើកសាច់ប្រាក់ពីធនាគារ**

កត់ត្រា÷

ឥណពន្ធ គណនី បេឡាសាច់ប្រាក់ (លេខ ១៣០១)

ឥណទាន គណនី មូលប្បទានប័ត្រធ្វើបេឡានិច្ច័យ (លេខ ១១១៦)។

**គ. ការបើកផ្តល់ចំណាយ**

កត់ត្រា÷

ឥណពន្ធ គណនី ចំណាយមុនការធ្វើអាណត្តិកិច្ច (លេខ ១៥០៥)

ឥណទាន គណនី បេឡាសាច់ប្រាក់ (លេខ ១៣០១)។

**ឃ. ការបញ្ជូនលិខិតយុត្តិការចំណាយនិងអាណត្តិនិយ័តកម្មទៅរតនាគារ**

កត់ត្រា÷

ឥណពន្ធ គណនី លិខិតយុត្តិការចំណាយបានបញ្ជូន (លេខ ១៥០៧)

ឥណទាន គណនី ចំណាយមុនការធ្វើអាណត្តិកិច្ច (លេខ ១៥០៥)។

**ង. ការទូទាត់រដ្ឋទេយ្យបុរេប្រទានយោងតាមការឯកភាពយល់ព្រមរបស់គណនេយ្យករសាធារណៈលើអាណត្តិនិយ័តកម្មនិងលិខិតយុត្តិការចំណាយ**

កត់ត្រា÷

ឥណពន្ធ គណនី បុរេប្រទានពីរតនាគារ (លេខ ១១១៨)

ឥណទាន គណនី លិខិតយុត្តិការចំណាយបានបញ្ជូន (លេខ ១៥០៧)។

**ច. ការបង់ប្រាក់ដែលនៅសល់ទៅគណនេយ្យករសាធារណៈ**

កត់ត្រា÷

ឥណពន្ធ គណនី បុរេប្រទានពីរតនាគារ (លេខ ១១១៨)

ឥណទានគណនី បេឡាសាច់ប្រាក់ (លេខ ១៣០១)។

រដ្ឋទេយ្យករបុរេប្រទានត្រូវរៀបចំប័ណ្ណចំណូល ប័ណ្ណចំណាយ លិខិតជូនដំណឹងឥណពន្ធ និងលិខិតជូនដំណឹងឥណទាន ទៅតាមប្រតិបត្តិការនីមួយៗ។

## ជំពូកទី៥
## ការត្រួតពិនិត្យរដ្ឋទេយ្យបុរេប្រទាន
### ផ្នែកទី១
### គោលការណ៍ទូទៅ

**ប្រការ២៧.-**

រដ្ឋទេយ្យបុរេប្រទានទាំងអស់ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យនៃអាណាប័ករបស់ខ្លួន។ ទន្ទឹមនេះ រដ្ឋទេយ្យករបុរេប្រទាន ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យផ្ទៀងផ្ទាត់ពីអគ្គាធិការដ្ឋាន និងពីអាជ្ញាធរមានសមត្ថកិច្ចត្រួតពិនិត្យនៅនឹងកន្លែង។

### ផ្នែកទី២
### ការត្រួតពិនិត្យលើលិខិតយុត្តិការ

**ប្រការ២៨.-**

អាណាប័ក មានភារកិច្ចត្រួតពិនិត្យដូចតទៅ÷

- អាណាប័កតម្រូវឱ្យរដ្ឋទេយ្យករបុរេប្រទានផ្តល់នូវតារាងតុល្យភាពគណនីនៃរដ្ឋទេយ្យបុរេប្រទានប្រចាំខែ ប្រចាំឆ្នាំ របាយការណ៍ និងកំណត់ហេតុត្រួតពិនិត្យផ្ទាល់នៅនឹងកន្លែងលើការងាររដ្ឋទេយ្យបុរេប្រទានដែលបានធ្វើឡើងដោយគណនេយ្យករសាធារណៈ
- អាណាប័កត្រូវពិនិត្យលិខិតយុត្តិការចំណាយដែលផ្តល់ដោយរដ្ឋទេយ្យករបុរេប្រទាននិងត្រូវធានាថាឯកសារទាំងឡាយមានការប្រគល់ទទួលត្រឹមត្រូវពិតប្រាកដរវាងរដ្ឋទេយ្យករបុរេប្រទាន និងអ្នកទទួលប្រាក់ ព្រមទាំងពិនិត្យថា រដ្ឋទេយ្យករបុរេប្រទានបានទូទាត់តែចំណាយណាដែលរដ្ឋទេយ្យបុរេប្រទានបានអនុញ្ញាតប៉ុណ្ណោះ។

**ប្រការ២៩.-**

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ មានភារកិច្ចត្រួតពិនិត្យ ដូចតទៅ÷

- រដ្ឋទេយ្យករបុរេប្រទានត្រូវផ្តល់ឱ្យមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនូវឯកសារចំណាយពាក់ព័ន្ធនឹងអាណត្តិនិយ័តកម្ម (លើកលែងចំពោះរដ្ឋបាលឃុំ សង្កាត់)
- មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុធ្វើការត្រួតពិនិត្យ និងផ្តល់ទិដ្ឋាការលើភាពត្រឹមត្រូវរបស់អាណត្តិនិយ័តកម្ម និងឯកសារចំណាយភ្ជាប់ (លើកលែងចំពោះរដ្ឋបាលឃុំ សង្កាត់)។

**ប្រការ៣០.-**

គណនេយ្យករសាធារណៈមានភារកិច្ចត្រួតពិនិត្យដូចតទៅ÷

- រដ្ឋទេយ្យករបុរេប្រទានត្រូវផ្តល់ឱ្យគណនេយ្យករសាធារណៈនូវតារាងតុល្យភាពគណនីនៃរដ្ឋទេយ្យបុរេប្រទាន ព្រមទាំងសំណុំឯកសារ ឬ ព័ត៌មានស្តីពីការងាររដ្ឋទេយ្យបុរេប្រទាន
- គណនេយ្យករសាធារណៈធ្វើការត្រួតពិនិត្យអាណត្តិនិយ័តកម្មនិងលិខិតយុត្តិការចំណាយ ដើម្បីទូទាត់ប្រាក់រដ្ឋទេយ្យបុរេប្រទានដែលបានចំណាយ ដូចអាណត្តិបើកប្រាក់តាមនីតិវិធីធម្មតាដែរ ដោយគណនេយ្យករ

សាធារណៈត្រូវត្រួតពិនិត្យបន្ថែមទៀតថា រដ្ឋទេយ្យករបុរេប្រទានបានធ្វើការទូទាត់តែចំណាយណា ដែលរដ្ឋទេយ្យបុរេប្រទានបានអនុញ្ញាតប៉ុណ្ណោះ។

## ផ្នែកទី៣
## ការត្រួតពិនិត្យដល់ទីកន្លែង

**ប្រការ៣១.-**

អាណាប័ក គណនេយ្យករសាធារណៈ អគ្គាធិការ និងមន្ត្រីនៃស្ថាប័នមានសមត្ថកិច្ចផ្សេងទៀតអាចធ្វើការត្រួតពិនិត្យ ឬ ផ្ទៀងផ្ទាត់នៅនឹងកន្លែងដោយផ្ទាល់លើការងារគ្រប់គ្រងរបស់រដ្ឋទេយ្យករបុរេប្រទាន។ ការត្រួតពិនិត្យត្រូវប្រព្រឹត្តទៅដោយមិនប្រាប់ឱ្យដឹងជាមុន។ អាណាប័កនិងគណនេយ្យករសាធារណៈអាចចាត់តាំងភ្នាក់ងារនៅក្រោមឱវាទដើម្បីធ្វើការត្រួតពិនិត្យផ្ទាល់នៅនឹងកន្លែង។ ភ្នាក់ងារនេះត្រូវមានលិខិតឧទ្ទេសនាមឬលិខិតបញ្ជាបេសកកម្មត្រឹមត្រូវ។

ការត្រួតពិនិត្យខាងលើត្រូវធ្វើលើចំណុច ជាអាទិ៍ ដូចខាងក្រោម៖

- មូលនិធិនិងតម្លៃ
- ការបញ្ឈប់និងផ្តល់ទិដ្ឋាការលើបញ្ជីទាំងឡាយ
- ការធ្វើតារាងតុល្យភាពគណនីរដ្ឋទេយ្យបុរេប្រទាន
- កិច្ចប្រតិបត្តិការគណនេយ្យនិងលិខិតយុត្តិការផ្សេងៗដែលមានការពាក់ព័ន្ធទៅនឹងការរៀបចំនិងកិច្ចដំណើរការរបស់រដ្ឋទេយ្យបុរេប្រទាន។

**ប្រការ៣២.-**

ការត្រួតពិនិត្យផ្ទាល់ដោយអាណាប័ក ឬ តំណាងត្រូវធ្វើឱ្យបានញឹកញាប់។ ជាគោលការណ៍ ការត្រួតពិនិត្យលើមូលនិធិនិងតម្លៃដែលបានអនុវត្តគឺត្រូវធ្វើក្នុង១ត្រីមាសម្តង។

ការត្រួតពិនិត្យរបស់គណនេយ្យករសាធារណៈ ត្រូវធ្វើយ៉ាងតិចបំផុត១ឆ្នាំម្តង។

រាល់ការត្រួតពិនិត្យមួយលើកៗ ត្រូវមានរបាយការណ៍ ឬ កំណត់ហេតុត្រឹមត្រូវច្បាស់លាស់ ដែលក្នុងនោះត្រូវកត់សម្គាល់នូវកិច្ចការដែលបានពិនិត្យឃើញ។ ឯកសារទាំងនោះត្រូវផ្តល់ឱ្យរដ្ឋទេយ្យករបុរេប្រទានធ្វើការកត់សម្គាល់និងផ្តល់នូវចម្លើយ ហើយត្រូវធ្វើត្រលប់ទៅភ្នាក់ងារត្រួតពិនិត្យនិងអាណាប័កវិញ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ៣៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាព

ក្រោមនិវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់ថ្នាក់រដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**គំរូឧបសម្ព័ន្ធទី១**

*(ឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីសម្រេចស្តីពីការបង្កើតវិជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលរាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ)*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ...**

**តារាងឧបសម្ព័ន្ធវិជ្ជទេយ្យបុរេប្រទានឆ្នាំ.....**

**របស់រដ្ឋបាលរាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ..**

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទាន វិជ្ជទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន០១ជុំបង្វិល វិជ្ជទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៦ជុំ (រាជធានី ខេត្ត)<br>៥=៣/៤ជុំ (ក្រុង ស្រុក ខណ្ឌ) | ៦=៣/២ |
| | | | **សរុបរួម** | | | | | | |
| *60* | | | ***ការទិញ*** | | | | | | |
| | *6001* | | *សម្ភារៈផ្គត់ផ្គង់ថែទាំ* | | | | | | |
| | | *60011* | | | | | | | |
| | ..... | ..... | | | | | | | |
| *61* | | | ***សេវាកម្ម*** | | | | | | |
| | ..... | ..... | | | | | | | |
| *62* | | | ***អត្ថប្រយោជន៍សង្គម*** | | | | | | |
| | ..... | ..... | | | | | | | |
| *65* | | | ***ឧបត្ថម្ភធន*** | | | | | | |
| | ..... | ..... | | | | | | | |

បានឃើញនិងពិនិត្យថាត្រឹមត្រូវ
ថ្ងៃទី.....ខែ.......ឆ្នាំ....
ប្រធានរតនាគាររាជធានី ខេត្ត....

បានឃើញនិងពិនិត្យថាត្រឹមត្រូវ
ថ្ងៃទី.....ខែ.......ឆ្នាំ....
ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ.....

បានឃើញនិងពិនិត្យថាត្រឹមត្រូវ
ថ្ងៃទី.....ខែ.......ឆ្នាំ....
នាយកទីចាត់ការហិរញ្ញវត្ថុ/ប្រធានការិយាល័យ

ថ្ងៃទី.....ខែ.......ឆ្នាំ....
វិជ្ជទេយ្យករបុរេប្រទាន

លេខ.................
បានឃើញនិង.......
ថ្ងៃទី.....ខែ.......ឆ្នាំ....
អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត/អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ....

**គំរូឧបសម្ព័ន្ធទី២**

*(ឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីសម្រេចស្តីពីការបង្កើតរដ្ឋទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលឃុំ សង្កាត់)*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឃុំ-សង្កាត់...**

**តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានឆ្នាំ.....**

**របស់រដ្ឋបាលឃុំ សង្កាត់...**

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានរដ្ឋទេយ្យបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទាន១ជុំបង្វិលរដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥= ៣/ ៤ជុំ | ៦= ៣/ ២ |
| | | | **សរុបរួម** | | | | | | |
| 60 | | | *ការទិញ* | | | | | | |
| | 6001 | | *សម្ភារៈផ្គត់ផ្គង់ថែទាំ* | | | | | | |
| | | 60011 | | | | | | | |
| | ..... | ..... | | | | | | | |
| 61 | | | *សេវាកម្ម* | | | | | | |
| | ..... | ..... | | | | | | | |
| 62 | | | *អត្ថប្រយោជន៍សង្គម* | | | | | | |
| | ..... | ..... | | | | | | | |
| 65 | | | *ឧបត្ថម្ភធន* | | | | | | |
| | ..... | ..... | | | | | | | |

បានឃើញនិងពិនិត្យថាត្រឹមត្រូវ
ថ្ងៃទី.....ខែ.......ឆ្នាំ....
ប្រធានរតនាគាររាជធានី ខេត្ត....

ថ្ងៃទី.....ខែ.......ឆ្នាំ....
រដ្ឋទេយ្យករបុរេប្រទាន

លេខ................
បានឃើញនិង.....
ថ្ងៃទី.....ខែ.......ឆ្នាំ....
មេឃុំ ចៅសង្កាត់....

**គំរូឧបសម្ព័ន្ធទី៣**

គំរូសេចក្តីសម្រេចស្តីពីការបង្កើតរដ្ឋទេយ្យបុរេប្រទាននៅសាលារាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ...

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតរដ្ឋទេយ្យបុរេប្រទានសម្រាប់ឆ្នាំ.....**

**នៅសាលារាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ..........**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ............ចុះថ្ងៃទី....... ខែ........ ឆ្នាំ....... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ.......
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ........ អនក្រ.បក ចុះថ្ងៃទី..... ខែ...... ឆ្នាំ..... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ......... (ក្រសួង/ស្ថាប័ន/អង្គភាព)
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញប្រកាសលេខ........ សហវ.ប្រក ចុះថ្ងៃទី........... ស្ដីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.–**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក៦០ “ការទិញ”, ជំពូក៦១ “សេវាកម្ម”, ជំពូក៦២ “អត្ថប្រយោជន៍សង្គម”, ជំពូក៦៥ “ឧបត្ថម្ភកធន” នៅសាលារាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ...សម្រាប់មុខសញ្ញាចំណាយ ដូចមានចែងក្នុងប្រការ៥ នៃប្រកាសលេខ....... សហវ.ប្រក ចុះថ្ងៃទី..... ស្ដីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃសេចក្ដីសម្រេចនេះ។

**ប្រការ២.–**

ចំនួនទឹកប្រាក់មួយជុំបង្វិល នៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ៣.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.–**

នាយករដ្ឋបាលរាជធានី/ខេត្ត......មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី/ខេត្ត.......រតនាគាររាជធានី/ខេត្ត.... សាលារាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ........ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ.......... ថ្ងៃទី ខែ ឆ្នាំ

**អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

**ក្រុង ស្រុក ខណ្ឌ...**

**កន្លែងទទួល÷**
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ជូនជ្រាប)
- ដូចប្រការ៤ (ដើម្បីមុខការ)

**គំរូឧបសម្ព័ន្ធទី៤**

គំរូសេចក្តីសម្រេចស្តីពីការបង្កើតរជ្ជទេយ្យបុរេប្រទាននៅឃុំ សង្កាត់...

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតរជ្ជទេយ្យបុរេប្រទានសម្រាប់ឆ្នាំ.....**

**នៅឃុំ សង្កាត់...........**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ............ចុះថ្ងៃទី....... ខែ........ ឆ្នាំ....... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ.......
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ........ អនក្រ.បក ចុះថ្ងៃទី..... ខែ...... ឆ្នាំ..... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ.........(ក្រសួង/ស្ថាប័ន/អង្គភាព)
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសណែនាំលេខ ៩៣៨ សហវ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០២ ស្តីពីប្រព័ន្ធទូទាត់និងគណនេយ្យឃុំសង្កាត់
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ........ សហវ.ប្រក ចុះថ្ងៃទី........... ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក៦០ "ការទិញ", ជំពូក៦១ "សេវាកម្ម", ជំពូក៦២ "អត្ថប្រយោជន៍សង្គម", ជំពូក៦៥ "ឧបត្ថម្ភធន" នៅឃុំ សង្កាត់...សម្រាប់មុខសញ្ញាចំណាយ ដូចមានចែងក្នុងប្រការ៥ នៃប្រកាសលេខ....... សហវ.ប្រក ចុះថ្ងៃទី........ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃសេចក្តីសម្រេចនេះ។

**ប្រការ២.-**

ចំនួនទឹកប្រាក់មួយជុំបង្វិល នៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

ប្រធានរតនាគាររាជធានី/ខេត្ត.... មេឃុំ ចៅសង្កាត់........ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើ....... ថ្ងៃទី ខែ ឆ្នាំ

**មេឃុំ-ចៅសង្កាត់...**

**កន្លែងទទួល÷**
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ជូនជ្រាប)
- ដូចប្រការ៤ (ដើម្បីមុខការ)

**គំរូឧបសម្ព័ន្ធទី៥**

គំរូសេចក្តីសម្រេចស្តីពីការតែងតាំងរដ្ឋលេខាធិការបុរេប្រទាននៅសាលារាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ

**សេចក្តីសម្រេច**

**ស្តីពី**

**ការតែងតាំងរដ្ឋលេខាធិការបុរេប្រទាន**

**នៅសាលារាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ............ ចុះថ្ងៃទី.....ខែ.......ឆ្នាំ......... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ.......
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ........ អនក្រ.បក ចុះថ្ងៃទី..... ខែ...... ឆ្នាំ..... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ.........(ក្រសួង/ស្ថាប័ន/អង្គភាព)
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល

- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ........សហវ.ប្រក ចុះថ្ងៃទី...........ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.-**

ត្រូវបានតែងតាំងមន្ត្រីរាជការ នៃសាលារាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ............ ដូចខាងក្រោម÷

១- លោក/លោកស្រី .............(ឈ្មោះ) .................. (មុខងារ) ជារជ្ជទេយ្យករបុរេប្រទាននៅ .........

២- លោក/លោកស្រី .............(ឈ្មោះ) ......................(មុខងារ) ជារជ្ជទេយ្យករបុរេប្រទានរងនៅ.........។

(តែងតាំងតាមការចាំបាច់)

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

សាលារាជធានី ខេត្ត...ក្រុង.. ស្រុក.... ខណ្ឌ... ប្រធានរតនាគាររាជធានី ខេត្ត.. ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើ......... ថ្ងៃទី ខែ ឆ្នាំ

**អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

**ក្រុង ស្រុក ខណ្ឌ....**

**កន្លែងទទួល÷**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ជូនជ្រាប)
- ដូចប្រការ៣ (ដើម្បីមុខការ)
- ឯកសារ-កាលប្បវត្តិ

**គំរូឧបសម្ព័ន្ធទី៦**

គំរូសេចក្តីសម្រេចស្តីពីការតែងតាំងរដ្ឋទេយ្យករបុរេប្រទាននៅឃុំ សង្កាត់....

**សេចក្តីសម្រេច**

**ស្តីពី**

**ការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន**

**នៅឃុំ សង្កាត់....**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ............ ចុះថ្ងៃទី.....ខែ.......ឆ្នាំ......... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ.......
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ........ អនក្រ.បក ចុះថ្ងៃទី..... ខែ...... ឆ្នាំ..... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ......... (ក្រសួង/ស្ថាប័ន/អង្គភាព)
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល

- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសណែនាំលេខ ៩៣៨ សហវ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០២ ស្តីពីប្រព័ន្ធទូទាត់និងគណនេយ្យឃុំសង្កាត់
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ........ សហវ.ប្រក ចុះថ្ងៃទី........... ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.-**

ត្រូវបានតែងតាំងមន្ត្រីរាជការ នៃឃុំ សង្កាត់........... ដូចខាងក្រោម÷

៣- លោក/លោកស្រី ............(ឈ្មោះ) ................. (មុខងារ) ជារជ្ជទេយ្យករបុរេប្រទាននៅ .........

៤- លោក/លោកស្រី ............(ឈ្មោះ) .....................(មុខងារ) ជារជ្ជទេយ្យករបុរេប្រទានរងនៅ.........។ (តែងតាំងតាមការចាំបាច់)

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

ប្រធានរតនាគាររាជធានី ខេត្ត មេឃុំ និងចៅសង្កាត់....... ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ............. ថ្ងៃទី ខែ ឆ្នាំ

**មេឃុំ ចៅសង្កាត់....**

**កន្លែងទទួល÷**
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ជូនជ្រាប)
- ដូចប្រការ៣ (ដើម្បីមុខការ)

ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
**លេខ** ០២៨៤ **ពណ.ចបព**

**ភ្នំពេញថ្ងៃទី** ១២ **ខែ**មករា **ឆ្នាំ** ២០១៥

# រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**ជំរាបមក**

លោក SHIN JIN KYUN   អភិបាលក្រុមហ៊ុន **ដឺ សែលវេសិន (ខេមបូឌា) អេសិត**

អាសយដ្ឋាន: លេខ ៥០៣ ផ្លូវលេខ ៩០BT សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

**<u>កម្មវត្ថុ</u>** : ករណីសុំកែប្រែ និងតម្កល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ដឺ សែលវេសិន (ខេមបូឌា) អេសិត** THE SALVATION ( CAMBODIA ) ASSET Co., Ltd.

**<u>យោង</u>** : -សំណើរបស់ក្រុមហ៊ុន          ចុះថ្ងៃទី ១៧ - ១២ - ២០១៤

-កំណត់ហេតុអង្គប្រជុំ និងសេចក្តីសម្រេចសម្ហហភាព ចុះថ្ងៃទី ១០ - ១២ - ២០១៤

-លក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុនចុះហត្ថលេខា  ថ្ងៃទី ១០ - ១២ - ២០១៤

-សេចក្តីប្រកាសស្តីពីការកែប្រែលក្ខន្តិកៈក្រុមហ៊ុនក្នុងព្រឹត្តិប័ត្រពាណិជ្ជកម្មលេខ ៥២៣ ចេញផ្សាយថ្ងៃទី ១៥ - ០១ - ២០១៥

តាមកម្មវត្ថុនិងយោងខាងលើនេះ ខ្ញុំសូមជំរាបលោកថា : ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការកែប្រែ និងតម្កល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ដឺ សែលវេសិន (ខេមបូឌា) អេសិត** THE SALVATION ( CAMBODIA ) ASSET Co., Ltd. ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 1396KH/2013 ចុះថ្ងៃទី 03 - 07 - 2013 ទៅតាមចំណុចដូចមានចែងក្នុងលិខិតស្នើ និងយោងខាងលើគឺ:

-ការលាលែងចេញសមាជិកហ៊ុនចំនួន ០៣ រូប គឺលោក **ម៉ិន ហេង** លោក **ទុំ អរុណា** និង លោក **មឿក ឈុនលីម**

-ការធ្វើអនុប្បទានភាគហ៊ុន

-ការបង្កើនដើមទុនចុះបញ្ជីពាណិជ្ជកម្ម :

-ដើមទុនចាស់ :      ២០.០០០.០០០ រៀល

-ដើមទុនថ្មី    :    ២.៤០០.០០០.០០០ រៀល

-ការបែងចែកជាភាគហ៊ុនចំនួន ១.០០០ ភាគហ៊ុន ដែល១ភាគហ៊ុនមានតម្លៃ ២.៤០០.០០០ រៀល

-សមាសភាពសមាជិកហ៊ុន និងការកាន់កាប់ភាគហ៊ុនថ្មី :

- លោក SHIN JIN KYUN  (សញ្ជាតិ កូរ៉េ)  កាន់កាប់ភាគហ៊ុនចំនួន ១.០០០ ភាគហ៊ុន

-ការលុបកម្មវត្ថុអាជីវកម្ម : -ទិញ លក់ ជួល បញ្ចាំម្ហូលនីធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លីផ្ទះសម្បែង

-ការប្តូរទ្រង់ទ្រាយក្រុមហ៊ុនពីក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ទៅជាសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

-ការប្តូរសញ្ជាតិក្រុមហ៊ុន :

ពីសញ្ជាតិ : ខ្មែរ

មកសញ្ជាតិ : បរទេស

និងប្តូរអត្តលេខចុះបញ្ជីពាណិជ្ជកម្មពី Co. 1396KH/2013 ចុះថ្ងៃទី 03 - 07 - 2013 ទៅជា Co. 1396E/2013 ចុះថ្ងៃទី 17 - 12 - 2014 ឯវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ ៥០៥៣ ពណ.ចុបព ចុះថ្ងៃទី ០៥ - ០៧ - ២០១៣ របស់ក្រសួងពាណិជ្ជកម្មត្រូវចាត់ទុកជានិរាករណ៍ ។

ប៉ុន្តែក្រុមហ៊ុនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ប្រសិនជាមានការតវ៉ាណាមួយទាក់ទងនឹងការកែប្រែលក្ខន្តិកៈក្រុមហ៊ុននេះ ។

អាស្រ័យហេតុនេះ សូមលោកជ្រាប និងអនុវត្តស្របទៅតាមច្បាប់ជាធរមាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**ឪម៉ុក-ប្រូជា**

**<u>ចម្លងជូន</u>** :

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងបរិស្ថាន
-ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ធនាគារជាតិនៃកម្ពុជា
-ក្រសួងសុខាភិបាល
-ក្រសួងពត៌មាន
-ក្រសួងអប់រំយុវជន និងកីឡា
-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
-ក្រសួងសាធារណការ និងដឹកជញ្ជូន
-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
-ក្រសួងទេសចរណ៍
-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
-អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
-អគ្គនាយកដ្ឋានពន្ធដារ
-សាលារាជធានីភ្នំពេញ
-មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
ស.ឥ -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០២៦៥ ពណ.ចបព

ភ្នំពេញថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៥

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### ជំរាបមក

លោក **អ៊ុង ប៊ីហួត** ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន **ឌី ឡូធើស ឌីវេឡុបម៉ិន លីមីធីត**
អាសយដ្ឋាន: អគារកាណាឌីយ៉ា បន្ទប់លេខ ២៦ A ជាន់ទី២៦ ផ្លូវលេខ ៣១៥ (ព្រះអង្គឌួង) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**កម្មវត្ថុ** : ករណីសុំកែប្រែ និងតម្កល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ឌី ឡូធើស ឌីវេឡុបម៉ិន លីមីធីត** D' LOTUS DEVELOPMENT LIMITED

**យោង** : -សំណើរបស់ក្រុមហ៊ុន ចុះថ្ងៃទី ២៤ - ១២ - ២០១៤
-កំណត់ហេតុអង្គប្រជុំ និងសេចក្តីសំរេចសមូហភាព ចុះថ្ងៃទី ១០- ១២ - ២០១៤
-លក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុនចុះហត្ថលេខា ថ្ងៃទី ១០ - ១២ - ២០១៤
-សេចក្តីប្រកាសស្តីពីការកែប្រែលក្ខន្តិកៈក្រុមហ៊ុនក្នុងព្រឹត្តិប័ត្រពាណិជ្ជកម្មលេខ ៥២៣ ចេញផ្សាយថ្ងៃទី ១៥ - ០១ - ២០១៥

តាមកម្មវត្ថុនិងយោងខាងលើនេះ ខ្ញុំសូមជំរាបលោកថា : ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការកែប្រែ និងតម្កល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ឌី ឡូធើស ឌីវេឡុបម៉ិន លីមីធីត** D' LOTUS DEVELOPMENT LIMITED ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 1106KH/2014 ចុះថ្ងៃទី 02 - 04 - 2014 ទៅតាមចំណុចដូចមានចែងក្នុងលិខិតស្នើ និងយោងខាងលើគឺ:

-ការប្តូរទីស្នាក់ការរបស់ក្រុមហ៊ុន :
-ទីស្នាក់ការចាស់ : លេខ A១ មហាវិថីសហាព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ប្តូរមកទីស្នាក់ការថ្មី: អគារកាណាឌីយ៉ា បន្ទប់លេខ ២៦ A ជាន់ទី២៦ ផ្លូវលេខ ៣១៥ (ព្រះអង្គឌួង) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-ការលាលែងចេញសមាជិកហ៊ុនចំនួន ០១រូប គឺលោក **តាំង គួច** " អភិបាលចាស់ "
-ការធ្វើអនុប្បទានភាគហ៊ុន
-សមាសភាពសមាជិកហ៊ុន និងការកាន់កាប់ភាគហ៊ុនថ្មី :
- លោក **អ៊ុង ប៊ីហួត** (សញ្ជាតិ : ខ្មែរ ) កាន់កាប់ភាគហ៊ុនចំនួន ៥១០ ភាគហ៊ុន
- ក្រុមហ៊ុន HLH DEVELOPMENT PTE..LTD. កាន់កាប់ភាគហ៊ុនចំនួន ៤៩០ ភាគហ៊ុន

ប៉ុន្តែក្រុមហ៊ុនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ប្រសិនជាមានការតវ៉ាណាមួយទាក់ទងនឹងការកែប្រែលក្ខន្តិកៈក្រុមហ៊ុននេះ ។

អាស្រ័យហេតុនេះ សូមលោកជ្រាប និងអនុវត្តស្របទៅតាមច្បាប់ជាធរមាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**អនុរដ្ឋលេខាធិការ**

**កុយ-សុដានី**

**ចម្លងជូន** :

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងបរិស្ថាន
-ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ធនាគារជាតិនៃកម្ពុជា
-ក្រសួងសុខាភិបាល
-ក្រសួងពត៌មាន
-ក្រសួងអប់រំយុវជន និងកីឡា
-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
-ក្រសួងសាធារណការ និងដឹកជញ្ជូន
-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
-ក្រសួងទេសចរណ៍
-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
-អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
-អគ្គនាយកដ្ឋានពន្ធដារ
-សាលារាជធានីភ្នំពេញ
-មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
សរ.៧ -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០២៥១ ពណ.ចបព

ភ្នំពេញថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៥

# រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រោមអត្តលេខ Co. ៣៨១២KH/២០១៤ ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៤ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណ: ច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅដោយយោងសេចក្តីប្រកាសរបស់ក្រុមហ៊ុន ដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ពូ ដុង ស៊ីរ៉ោន ឡេក លែន ឌីវេឡុបម៉ិន**
**PU DONG SURROUND LAKE LAND DEVELOPMENT Co., Ltd.**
មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន :

| | | |
|---|---|---|
| លោក | HSU, HUNG-MING ( SUNNY HSU ) | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក | CHUO, CHIAO | អភិបាល |
| លោកស្រី | WU, YUEH-MEI | អភិបាល |
| លោក | KUO, CHANG-CHI | អភិបាល |
| កញ្ញា | **ឈូ ម៉ាលី** | អភិបាល |
| លោកស្រី | **សេង ហ្គិចអ៊ាង** | អភិបាល |

៣- ដើមទុនក្រុមហ៊ុន : ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១២៧ Eo ផ្លូវលេខ ១៣ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
- ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ
- នាំចូលឱសថ សម្ភារ:បរិក្ខារពេទ្យគ្រប់ប្រភេទ
- ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសម្ភារ:ទំនិញគ្រប់ប្រភេទ
- ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
- ប្តូរប្រាក់ កែច្នៃ ទិញ លក់ គ្រឿងអលង្ការ
- មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
- បើកសាលារៀន
- ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
- សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
- សេវាកេការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
- សេវាផ្នែកព័ត៌មានវិទ្យា
- សេវាផ្សាយពាណិជ្ជកម្ម
- បោះពុម្ពផ្សាយ
- ផលិតខ្សែភាពយន្ត វីដេអូ CD ៥ ០/

- ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
- សេវាយកកម្រៃជើងសាលើការដឹកជញ្ជូន
- សាងសង់ ជួសជុល អគារ ស្ពាន ផ្ដល់-ស្ថាបត្យកម្ម រចនាប្លង់ ត្រួតពិនិត្យ និងសិក្សាគម្រោងប្លង់សំណង់គ្រប់ប្រភេទ
- ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកម្សាន្ត
- វិនិយោគលើវិស័យកសិកម្ម: ដាំដំណាំ ចិញ្ចឹមសត្វ
- វិនិយោគលើវិស័យឧស្សាហកម្ម: រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។៥

**ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**អ៊ឹក_ប្រុង**

**<u>ចម្លងជូន:</u>**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសុខាភិបាល
- ក្រសួងបរិស្ថាន
- ក្រសួងទេសចរណ៍
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងព័ត៌មាន
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានពន្ធដារ
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ក.ស.ន - ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ  សាសនា  ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
**លេខ** ០២៤៧ **ពណ.ចបព**

**ភ្នំពេញថ្ងៃទី** ១២ **ខែ** មករា **ឆ្នាំ ២០**១៥

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុន China Agriculture International Development Co., Ltd. (ចិន) ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រោមអត្តលេខ **Co. ៣៧៥០E/២០១៤** ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១៤ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ ដោយយោងសេចក្តីប្រកាសរបស់ក្រុមហ៊ុនដូចខាងក្រោម:

| | | |
|---|---|---|
| ១- នាមករណ៍របស់ក្រុមហ៊ុន | : | **ខេដកូ (ខេមបូឌា)**<br>**CAIDCO (CAMBODIA) Co., Ltd.** |
| មានទ្រង់ទ្រាយជា | : | សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត |
| ២- អភិបាលក្រុមហ៊ុន | : | លោក FAN QIDONG " តតិយជន |
| ៣- ដើមទុនក្រុមហ៊ុន | : | ៤០០.០០០.០០០ រៀល |
| ៤- ទីស្នាក់ការក្រុមហ៊ុន | : | ពេរខ E១៩ ក្រុម១០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ |
| ៥- កម្មវត្ថុអាជីវកម្ម | : | -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ពិសេស ចំណីសត្វ គ្រាប់ពូជ និងជីកសិកម្ម -នាំចូលឱសថ សម្ភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ<br>-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសម្ភារៈទំនិញគ្រប់ប្រភេទ<br>-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង<br>-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ<br>-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ<br>-បើកសាលារៀន<br>-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម<br>-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម<br>-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស<br>-សេវាផ្នែកព័ត៌មានវិទ្យា<br>-សេវាផ្សាយពាណិជ្ជកម្ម<br>-បោះពុម្ពផ្សាយ<br>-ផលិតខ្សែភាពយន្ត វីដេអូ CD<br>-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ |

-សេវាយកកម្រៃជើងសាលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់  - ស្ថាបត្យកម្ម រចនាប្លង់ ត្រួតពិនិត្យ និងសិក្សាគម្រោងប្លង់សំណង់គ្រប់ប្រភេទ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកម្សាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**ឡឹក_ប្រុជា**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងព័ត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- អគ្គនាយកដ្ឋានពន្ធដារ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "

ພ.ស.រ - ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
**លេខ** ០២៨៨ **ពណ.ចបព**

ភ្នំពេញថ្ងៃទី ១២ ខែមករា ឆ្នាំ ២០ ១៥

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រោមអត្តលេខ Co. ០០៦៤E/២០១៥ ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០១៥ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈ ច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ ដោយយោងសេចក្តីប្រកាសរបស់ក្រុមហ៊ុនដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេធើលីយេ អហ្វ អឺបេន អាឃីតេកឈ័រ អេនជីនារីង**
**ATELIER OF URBAN ARCHITECTURE ENGINEERING Co., Ltd.**
មានទម្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត
២- អភិបាលក្រុមហ៊ុន : លោកស្រី JIANG, SHU
៣- ដើមទុនក្រុមហ៊ុន : ២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន : រ៉ូសហ្គាដិន អឹជាតម៉ិន លេខ ២៥២ (អគារ C ជាន់ផ្ទាល់ដី បន្ទប់លេខ C ១៩០២) មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។
៥- កម្មវត្ថុអាជីវកម្ម :
- សេវាតុបតែង លម្អ អគារ លំនៅដ្ឋាន
- ពាណិជ្ជកម្ម: ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហារ័ណ អាហារ័ណទំនិញគ្រប់ប្រភេទ
- នាំចូលឱសថ សម្ភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
- ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសម្ភារៈទំនិញគ្រប់ប្រភេទ
- ប្តូរប្រាក់ កែច្នៃ ទិញ លក់ គ្រឿងអលង្ការ
- មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
- បើកសាលារៀន
- ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
- សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
- សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
- សេវាផ្នែកព័ត៌មានវិទ្យា
- សេវាផ្សាយពាណិជ្ជកម្ម
- បោះពុម្ពផ្សាយ
- ផលិតខ្សែភាពយន្តវីដេអូ CD
- ដឹកជញ្ជូន: ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
- សេវាយកកម្រៃជើងសាលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់-ស្ថាបត្យកម្ម រចនាប្លង់ ត្រួតពិនិត្យ និងសិក្សាគម្រោងប្លង់សំណង់គ្រប់ប្រភេទ

-ទេសចរណ៍: សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកម្សាន្ត

-វិនិយោគលើវិស័យកសិកម្ម: ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម: ជាងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

រដ្ឋលេខាធិការ

អ៊ុក_ប្រ៊ុជា

**<u>ចម្លងជូន:</u>**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសុខាភិបាល
- ក្រសួងបរិស្ថាន
- ក្រសួងទេសចរណ៍
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងព័ត៌មាន
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- អគ្គនាយកដ្ឋានពន្ធដារ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ក.ស.ន - ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០២៤៩ ពណ.ចបព

ភ្នំពេញថ្ងៃទី ១២ ខែ ០៧ ឆ្នាំ ២០១៥

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
### សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុន Hunan Global Group Co., Ltd. (ចិន) ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រោមអត្តលេខ Co. ៣៩២១E/២០១៤ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១៤ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ ដោយយោងសេចក្តីប្រកាសរបស់ក្រុមហ៊ុនដូចខាងក្រោម:

១- នាមករណ៍របស់ក្រុមហ៊ុន : គ្លូបិល អ៊ីខឡូជីខល រ៉ាយស៍ (ខេមបូឌា)
GLOBAL ECOLOGICAL RICE (CAMBODIA) Co., Ltd.
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត
២- អភិបាលក្រុមហ៊ុន : លោក ZHAI MU QI "គតិយជន"
៣- ដើមទុនក្រុមហ៊ុន : ៨.០០០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១៧៨ABCD មហាវិថីម៉ៅសេទុង សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ។
៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ
-នាំចូលឱសថសម្ភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសម្ភារៈទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាផ្នែកព័ត៌មានវិទ្យា
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្តវីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកម្រៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់ -សាមសូកម្ម ចេនាប្លង់ ត្រួតពិនិត្យ និងសិក្សាគម្រោងប្លង់សំណង់គ្រប់ប្រភេទ ។

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកម្សាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

អ៊ុក-ប្រ៊ុជា

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- អគ្គនាយកដ្ឋានពន្ធដារ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ - កាលប្បវត្តិ

ឃ.ស.ក